USAID
FROM THE AMERICAN PEOPLE

# ការបណ្ដុះបណ្ដាលអំពីការកត់ត្រាបញ្ជី សម្រាប់ អ្នកចិញ្ចឹមជ្រូក និងគ្រួសាររបស់ពួកគេ

ថ្ងៃទី ១០ តុលា ២០០៨

កាលបរិច្ឆេទ : ថ្ងៃទី ១០ តុលា ២០០៨

សៀវភៅនេះ ត្រូវបានរៀបចំឡើងសម្រាប់ការពិនិត្យរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។ សៀវភៅនេះ ត្រូវបានចងក្រងឡើងដោយលោក Phil Psilos សម្រាប់គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម កម្ពុជា ដែលអនុវត្តដោយ DAI ។

**កិច្ចសន្យាលេខ GEG-I-00-02-00014-00 លេខរៀងកិច្ចការ ០២**

**គម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម នៅកម្ពុជា (MSME)**

**សេចក្តីបញ្ជាក់ :**

ទស្សនៈរបស់អ្នកនិពន្ធដែលបានបង្ហាញនៅក្នុងសៀវភៅនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬទស្សនៈរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។

## សេចក្តីផ្តើម

សៀវភៅណែនាំនេះ ផ្តល់នូវការពន្យល់ត្រួសៗ ផែនការ និងឯកសារសម្រាប់កម្មវិធីបណ្តុះបណ្តាលដល់អ្នកចិញ្ចឹមជ្រូក អាជីវករទិញលក់ជ្រូក និងក្រុមគ្រួសាររបស់ពួកគេ ក្នុងការកត់ត្រាបញ្ជីចំណូល និងចំណាយ ។ សៀវភៅនេះត្រូវបានតាក់តែងឡើងជាផ្នែកមួយនៃគម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម នៅកម្ពុជា (MSME) ដែលត្រូវបានឧបត្ថម្ភមូលនិធិដោយសហរដ្ឋអាមេរិក និងអនុវត្តដោយអង្គការ ឌី អេ អាយ អភិវឌ្ឍន៍ ។

ប្រព័ន្ធកត់ត្រាបញ្ជីដែលបង្រៀននៅក្នុងនេះ ត្រូវបានរៀបចំតាក់តែងឡើងដោយបុគ្គលិកគម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម បន្ទាប់ពីការពិគ្រោះយោបល់ជាមួយធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួន ដែលបានផ្តល់យោបល់អំពីប្រភេទនៃប្រព័ន្ធកត់ត្រាបញ្ជីដែលនឹងធ្វើអោយពួកគេមានភាពងាយស្រួលក្នុងការផ្តល់ប្រាក់កម្ចីដល់សហគ្រាសអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម ដែលធ្វើអាជីវកម្មចិញ្ចឹមជ្រូក ។ ខណៈដែលការកត់ត្រាបញ្ជីដែលមានភាពទូលំទូលាយ ច្រើនថែមទៀតសម្រាប់សហគ្រាសនិងអាជីវកម្មជាលក្ខណៈគ្រួសារ គឺជាគោលដៅចុងក្រោយនៃកិច្ចប្រឹងប្រែងរបស់យើង គំរូ/ទម្រង់នៃការកត់ត្រាបញ្ជីដែលមាននៅក្នុងទំព័រទាំងនេះគឺជាជំហានដំបូង បង្អស់នៃការកត់ត្រាបញ្ជីលំហូរសាច់ប្រាក់អាជីវកម្ម (គណនេយ្យ) សម្រាប់សហគ្រិនដែលមានមុខរបរតូចតាច និងមានជំនាញផ្នែកលេខនព្វន្តទាប ។

## ការបណ្តុះបណ្តាល : សេចក្តីសង្ខេប

ខ្លឹមសារនៅក្នុងសៀវភៅនេះត្រូវបានតាក់តែងឡើងដើម្បីធ្វើអោយកិច្ចការពន្យល់អំពីការកត់ត្រាបញ្ជីមានភាពងាយស្រួលសម្រាប់អ្នកសម្របសម្រួល ។ ការណែនាំសម្រាប់អ្នកបណ្តុះបណ្តាលត្រូវបានសរសេរ នៅក្នុង ប្រអប់ ។ សំណួរសំខាន់ៗនៅក្នុងការបណ្តុះបណ្តាលពីដើមដល់ចប់ត្រូវបានសរសេរជាអក្សរ **ដិត** ហើយចម្លើយដែលគេរំពឹងទុកត្រូវបានសរសេរជាអក្សរ ***ទ្រេត*** ។ ទោះបីជាយ៉ាងណាក៏ដោយ នេះមិនមែនមានន័យថា គេត្រូវសួរ ឬឆ្លើយនូវសំណួរឬចម្លើយដែលមានសរសេរនៅក្នុងនេះតែប៉ុណ្ណោះនោះទេ ។ អ្នកសម្របសម្រួលអាចពិនិត្យទៅលើបញ្ហានានាទៅតាមតម្រូវការចង់ចេះចង់ដឹងរបស់សិក្ខាកាម ។ ចំណុចសំខាន់ៗដែលត្រូវរៀន ក៏ត្រូវបានរួមបញ្ចូលនៅក្នុងចំណុចនានានៅក្នុងផែនការវគ្គបណ្តុះបណ្តាលផងដែរ ។ សិក្ខាកាមត្រូវគេរំពឹងអោយផ្តោតការយកចិត្តទុកដាក់ទៅលើព័ត៌មានជាច្រើននៅក្នុងវគ្គបណ្តុះបណ្តាល ហើយជារឿយៗ ការពង្រឹងនូវចំណុចដែលត្រូវរៀននៅចន្លោះវគ្គគឺជាជំនួយស្មារតីដល់សិក្ខាកាម ។

នៅផ្នែកខាងក្រោយនៃសៀវភៅនេះមានឧបសម្ព័ន្ធជាច្រើន ។ ព័ត៌មាននៅក្នុងទំព័រឧបសម្ព័ន្ធទាំងនេះត្រូវបានតាក់តែងសម្រាប់អ្នករៀនដែលមានជំនឿចិត្តច្រើនក្នុងកិច្ចការកត់ត្រាបញ្ជី ហើយពួកគេទំនងជានឹងអាចបំពេញលំហាត់បានលឿនជាងអ្នកដែលមិនចេះអំពីការកត់ត្រាបញ្ជីសោះ ។ នៅក្នុងតារាងខាងក្រោមនេះ គឺជាប្រធានបទ ឬមុខវិជ្ជាដែលត្រូវបង្រៀននៅក្នុងវគ្គបណ្តុះបណ្តាលទាំងមូល និង ពេលវេលាដែលកំណត់សម្រាប់ការធ្វើបទបង្ហាញ ឬការធ្វើលំហាត់ ។ ពេលវេលាទាំងនេះគឺគ្រាន់តែជាការប៉ាន់ស្មានប្រហាក់ប្រហែលប៉ុណ្ណោះ ដោយអាចមានក្រុមខ្លះត្រូវប្រើពេលវេលាយូរជាងនេះ ឬក្រុមខ្លះអាចបញ្ចប់លំហាត់បានលឿនជាងនេះ អាស្រ័យទៅតាមកម្រិតនៃជំនឿចិត្តរបស់ពួកគេទៅលើប្រធានបទ ឬមុខវិជ្ជានីមួយៗ ។

ជាទីបញ្ចប់ ពេលវេលាសម្រាប់ការឈប់សម្រាកខ្លីៗនៅក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាល ឬសម្រាប់ការទទួលទានអាហារថ្ងៃត្រង់ ពុំត្រូវបានកំណត់ឡើយ ។ ពេលវេលាសម្រាប់ការឈប់សម្រាកទាំងនេះនឹងអាស្រ័យទៅលើភាពរីកចម្រើនរបស់សិក្ខាកាមក្នុងការចាប់បានខ្លឹមសារដែលបង្រៀន ហើយអ្នកសម្របសម្រួលជាអ្នកសម្រេចអំពីពេលវេលាដែលសមស្របសម្រាប់ការឈប់សម្រាក ។

| មុខវិជ្ជា | លេខទំព័រ | ពេលវេលា |
|---|---|---|
| សេចក្តីផ្តើមអំពីប្រព័ន្ធកត់ត្រាបញ្ជីសម្រាប់អ្នកសម្របសម្រួល | 4 | --- |
| មេរៀនទី១ : មូលហេតុអ្វីបានជាត្រូវធ្វើការកត់ត្រាបញ្ជី ? | 8 | ២០ នាទី |
| មេរៀនទី២ : លំហាត់ ការពិភាក្សាអំពីការកត់ត្រាបញ្ជី | 10 | ៤៥ នាទី |
| មេរៀនទី៣ : ប្រភេទខុសៗគ្នានៃការចំណាយ | 12 | ៣០ នាទី |
| មេរៀនទី៤ : លំហាត់ជ្រើសរើសប្រភេទនៃការចំណាយ | 15 | ២០ នាទី |
| កញ្ចប់ឯកសារ ទី១ : លំហាត់ជ្រើសរើសប្រភេទនៃការចំណាយ | 16 | |
| មេរៀនទី៥ : ការចុះបញ្ជីការចំណាយ និងតម្លៃ | 17 | ២៥ នាទី |
| ឯកសារចែកចាយ ទី២ : លំហាត់អនុវត្តន៍អំពីប្រភេទនៃការចំណាយដោយបញ្ចូលតួលេខ | 18 | |
| មេរៀនទី៦ : ការបំពេញបញ្ជីចំណាយប្រចាំខែ | 19 | ១៥ នាទី |
| មេរៀនទី៧ : ការបូកសរុបតាមកូឡោននីមួយៗ | 22 | ២០ នាទី |
| មេរៀនទី៨ : ទំព័រសង្ខេបចំណូល និងចំណាយប្រចាំខែ | 23 | ១៥ នាទី |
| ឯកសារចែកចាយ ទី៣ : សង្ខេបចំណាយប្រចាំឆ្នាំសម្រាប់អាជីវកម្មចិញ្ចឹមជ្រូកបំប៉នយកសាច់ | 27 | ១៥ នាទី |
| មេរៀនទី៩ : លំហាត់អនុវត្តន៍អំពីការចំណាយក្នុងខែផ្សេងមួយទៀត | 26 | ២០ នាទី |

ឯកសារចែកចាយ ទី៤ : ការចំណាយនៅក្នុងខែផ្សេងមួយទៀតសម្រាប់អាជីវកម្មចិញ្ចឹមជ្រូកបំប៉នយកសាច់ 27

មេរៀនទី១០ : ការពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗ ១០ នាទី

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១ : ការណែនាំសម្រាប់អ្នកចិញ្ចឹមជ្រូក និងអាជីវករទិញលក់ជ្រូក ដែលមានបទពិសោធន៍ក្នុងការកត់ត្រាបញ្ជី 29/30

បញ្ជីថ្លៃលក់ និងការចំណាយប្រចាំខែសម្រាប់កិច្ចប្រតិបត្តិការចិញ្ចឹមជ្រូកបំប៉នយកសាច់ 31

បញ្ជីថ្លៃលក់ និងការចំណាយប្រចាំខែសម្រាប់កិច្ចប្រតិបត្តិការបង្កាត់ពូជនិងចិញ្ចឹមជ្រូកបំប៉នយកសាច់ 32

បញ្ជីថ្លៃលក់ និងការចំណាយប្រចាំខែសម្រាប់កិច្ចប្រតិបត្តិការទិញ-លក់ជ្រូក 33

សង្ខេបថ្លៃលក់ និងការចំណាយប្រចាំឆ្នាំសម្រាប់កិច្ចប្រតិបត្តិការចិញ្ចឹមជ្រូកបំប៉នយកសាច់ 34

សង្ខេបថ្លៃលក់ និងការចំណាយសម្រាប់កិច្ចប្រតិបត្តិការបង្កាត់ពូជ និងចិញ្ចឹមជ្រូកបំប៉នយកសាច់ 35

សង្ខេបថ្លៃលក់ និងការចំណាយប្រចាំឆ្នាំសម្រាប់កិច្ចប្រតិបត្តិការទិញ-លក់ជ្រូក 36

## សេចក្តីផ្តើមអំពីទម្រង់នៃការកត់ត្រាបញ្ជីសម្រាប់អ្នកសម្របសម្រួល ៖

ទម្រង់បញ្ជីដែលយើងបង្ហាញនៅក្នុងនេះ យក"សៀវភៅបញ្ជីសាច់ប្រាក់" រួមបញ្ចូលគ្នាជាមួយប្រព័ន្ធគណនេយ្យធម្មតាមួយ។ "សៀវភៅបញ្ជីសាច់ប្រាក់" ជាប្រភេទបញ្ជីចំណូល និងចំណាយដែលប្រព័ន្ធបណ្តុះបណ្តាលផ្នែកអាជីវកម្មជាច្រើនផ្តោតទៅលើ ។ "សៀវភៅគណនី" គឺជាប្រព័ន្ធនៃការកត់ត្រាបញ្ជីមួយដែលមានលក្ខណៈទំនើបជាង ហើយការបង្រៀនប្រព័ន្ធនេះដល់អាជីវកម្មខ្នាតតូចអាចមានភាពលំបាកខ្លាំងណាស់ ។ ប៉ុន្តែទោះជាយ៉ាងណា អ្នកចិញ្ចឹមជ្រូក និងអាជីវករលក់-ទិញជ្រូក ជាទូទៅមានប្រភេទចំណាយធម្មតាៗ ដូចជា ការចំណាយលើថ្លៃទិញសត្វ ចំណីសត្វ ឱសថ វ៉ាក់សាំង ឧបករណ៍ ពលកម្ម អគារ និងការថែទាំ ។ ម្យ៉ាងទៀត ការលក់របស់ពួកគេមានត្រឹមតែជ្រូក ឬ ម្តងម្កាល ផលិតផលចំណីសត្វ ។

ដូច្នេះហើយ ការរៀបចំបង្កើតប្រព័ន្ធកត់ត្រាបញ្ជី"ផ្អែកលើប្រព័ន្ធគណនេយ្យ"ដ៏សាមញ្ញមួយសម្រាប់អ្នកចិញ្ចឹមជ្រូក គឺជាការសមស្រប ហើយអនុញ្ញាតអោយអ្នកប្រើប្រាស់អាចចាប់ផ្តើមចាត់ប្រភេទនៃការចំណាយរបស់ពួកគេបានភ្លាមៗ ដើម្បីបង្កើតជាបញ្ជីចំណាយមួយដែលមានអត្ថន័យពិតប្រាកដនៅក្នុងការវិភាគកិច្ចដំណើរការអាជីវកម្មនិងលទ្ធភាពរកប្រាក់ចំណេញ ។

ទម្រង់សំខាន់ៗទាំង ២ ដែលត្រូវបានប្រើប្រាស់នៅក្នុងប្រព័ន្ធកត់ត្រាបញ្ជីនេះ រួមមាន ៖

**បញ្ជីចំណូល និងចំណាយប្រចាំខែ**



**បញ្ជីសង្ខេបចំណូល និងចំណាយប្រចាំខែ**



## គំរូបញ្ជីដែលបំពេញរួចសម្រាប់មួយខែ

ប្រព័ន្ធកត់ត្រាបញ្ជីនេះ រួមជាមួយគំរូនៃកិច្ចការសម្រាប់រយៈពេលមួយខែ ត្រូវបានបង្ហាញខាងក្រោមនេះសម្រាប់ ***អាជីវកម្មចិញ្ចឹមជ្រូកបំប៉នយកសាច់*** ។ (គំរូនៃការកត់ត្រាបញ្ជីសម្រាប់អាជីវកម្មជ្រូកប្រភេទផ្សេងៗទៀត ត្រូវបានបង្ហាញនៅពេលក្រោយក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាល) ។

ខែកញ្ញា ឆ្នាំ២០០៨

| | | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ថ្លៃលក់ |
|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាកសាំង | ឧបករណ៍ និង សម្ភារៈផ្សេងៗ | ពលកម្ម | អគារ និង ការថែទាំ | |
| **កាលបរិច្ឆេទ** | **បរិយាយ** |  |  |  |  |  |  |  |
| 1/9 | កូនជ្រូក ៥ក្បាលពីឈ្មោះ សុខ នៅក្នុងឃុំ | $300 | | | | | | |
| 10/9 | ចំណីសត្វម៉ាក Medivet ៦០គ.ក. ពីអ្នកលក់នៅក្នុងភូមិ | | $50 | | | | | |
| 11/9 | វ៉ាក់សាំងពីអ្នកលក់ក្នុងភូមិ | | | $20 | | | | |
| 18/9 | បើកលុយអោយ សុផាត សម្រាប់ថ្លៃសម្អាតទ្រុង | | | | | $3 | | |
| 20/9 | សម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូក | | | | | | $8 | |
| 26/9 | ទិញឧបករណ៍ដាក់ទឹកអោយជ្រូកផឹកថ្មីចំនួន ៣ | | | | $4 | | | |
| 29/9 | ទិញឱសថព្យាបាលជ្រូកឈឺ | | | $5 | | | | |
| 30/9 | លក់ជ្រូក ៦ក្បាល ៩០គ.ក. ទៅអោយ អ្នកប្រមូលទិញជ្រូកឈ្មោះ តារា | | | | | | | $1150 |
| | សរុបសម្រាប់ខែនេះ | $300 | $50 | $25 | $4 | $3 | $8 | $1150 |

## គំរូបញ្ជីសង្ខេបប្រចាំខែដែលបំពេញរួច :

នៅចុងខែនីមួយៗ អ្នកចិញ្ចឹមជ្រូកអាចផ្ទេរលទ្ធផលនៃការកត់ត្រាបញ្ជីរបស់ខ្លួនចូលក្នុងបញ្ជីសង្ខេបការចំណាយមួយ ដែលនឹងក្លាយជារបាយការណ៍លំហូរសាច់ប្រាក់ប្រចាំឆ្នាំដ៏មានសារប្រយោជន៍ ។

| | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | | ថ្លៃលក់ |
|---|---|---|---|---|---|---|---|---|
| | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈផ្សេងៗ | ពលកម្ម | អគារ និងការថែទាំ | ការចំណាយសរុប | |
| **ខែ** |  |  |  |  |  |  | **ដុល្លារ/រៀល** |  |
| មិថុនា | | | | | | | | |
| កក្កដា | | | | | | | | |
| សីហា | | ការចំណាយសម្រាប់ប្រភេទនីមួយៗ ត្រូវបានបូកសរុបចូលគ្នា (សរុប) | | | | | | |
| កញ្ញា | ៣០០ ដុល្លារ | ៥០ ដុល្លារ | ២៥ ដុល្លារ | ៤ ដុល្លារ | ៣ ដុល្លារ | ៨ ដុល្លារ | ៣៨៥ ដុល្លារ | ១១៥០ ដុល្លារ |
| តុលា | | | | | | | | |
| វិច្ឆិកា | | | | | | | | |
| ធ្នូ | | | | | | | | |
| **សរុប** | | | | | | | | |

**ឯកសារបន្ថែម**

ឯកសារបណ្តុះបណ្តាលនេះ ក៏រួមមានទម្រង់កត់ត្រាបញ្ជីដែលមិនទាន់បំពេញសម្រាប់ចំណូលនិងចំណាយប្រចាំខែនិងប្រចាំឆ្នាំ សម្រាប់ប្រភេទនៃអាជីវកម្មជ្រូកចំនួន ៣ ផ្សេងៗគ្នាផងដែរ ។ ទម្រង់ទាំងនេះត្រូវបានអោយឈ្មោះថា "ទម្រង់ ១" និង "ទម្រង់ ២" សម្រាប់ប្រភេទអាជីវកម្មនីមួយៗ ។

- អ្នកចិញ្ចឹមជ្រូកបំប៉នយកសាច់ ដែលទិញកូនជ្រូកយកមកចិញ្ចឹមអោយធំធាត់ រួចហើយលក់ទៅអោយអ្នកកាប់សាច់ ។
- អ្នកផលិតជ្រូក ដែលចិញ្ចឹមជ្រូកមេបង្កើតយកកូនលក់អោយកសិករដទៃទៀត ឬដែលផលិតកូនជ្រូកដើម្បីចិញ្ចឹមបំប៉នអោយធំដោយខ្លួនឯង ។
- អាជីវករទិញ-លក់ជ្រូក (អ្នកប្រមូលទិញ ឬឈ្មួញកណ្តាល) ដែលទិញជ្រូករស់រួចហើយលក់បន្តទាំងជ្រូកនៅរស់ទៅអោយអាជីវករផ្សេងទៀត ឬកាប់យកសាច់លក់ទៅអោយតូបលក់រាយ ឬតូបលក់ដុំនៅក្នុងផ្សារ ។

ដោយសារការចំណាយជាធម្មតា (ស្តង់ដារ) សម្រាប់អាជីវកម្មទាំងនេះមានលក្ខណៈខុសគ្នា គេក៏ត្រូវការនូវទម្រង់នៃការកត់ត្រាបញ្ជីខុសៗគ្នាដែរ ។

**តើចំណេះដឹងនិងជំនាញអ្វីខ្លះដែលអ្នកចិញ្ចឹមជ្រូកនិងគ្រួសាររបស់ពួកគេត្រូវការ ដើម្បីប្រើប្រាស់ប្រព័ន្ធកត់ត្រាបញ្ជីនេះបាន ?**

ចំណេះដឹង :

១) ហេតុអ្វីបានជាការកត់ត្រាបញ្ជីមានសារសំខាន់ ?

២) តើអ្វីទៅជាតារាង ?

៣) តើការចំណាយប្រភេទណាខ្លះ ដែលត្រូវចុះនៅក្នុងប្រភេទនៃការចំណាយផ្សេងៗគ្នា

៤) តើត្រូវកត់ត្រាការចំណាយនៅកន្លែងណា បើការចំណាយនោះហាក់ដូចជាមិនត្រូវនឹងប្រភេទចំណាយដទៃទៀតទេនោះ

៥) ភាពខុសគ្នារវាង*ទម្រង់បញ្ជីប្រចាំខែ* (ទម្រង់ ១) និង *ទម្រង់បញ្ជីសង្ខេបប្រចាំខែ/ប្រចាំឆ្នាំ* (ទម្រង់ ២) ។

ជំនាញ :

១) ការប្រើប្រាស់តារាង

២) ការសរសេរកាលបរិច្ឆេទនៅក្នុងតារាង

៣) ការសរសេរបរិយាយអំពីបរិមាណ និងទម្ងន់ នៅក្នុងតារាង ឬការប្រើសញ្ញាជារូបភាពជំនួសការបរិយាយ ក្នុងករណីអ្នកមិនសូវចេះអក្សរ ។

៤) ការសរសេរអំពីចំណាយនៅក្នុងកូឡោនសមស្រប

៥) ការបូកបញ្ចូលគ្នា (សរុប) ការចំណាយទាំងអស់នៅក្នុងកូឡោនមួយ និងការចុះចំនួនសរុបនៅក្នុងប្រអប់នៅផ្នែកខាងក្រោមបំផុតនៃទំព័រ

៦) ការចុះចំនួនសរុបពីកូឡោននីមួយៗនៃតារាងទៅក្នុងប្រអប់ត្រឹមត្រូវនៅលើបញ្ជីសង្ខេប ។

៧) ការបូកបញ្ចូលគ្នា (សរុប) នូវការចំណាយឆ្លងជួរ និងចុះចំនួនសរុបនៅក្នុងប្រអប់ "ចំណាយសរុប" ។

ដោយសារតែជំនាញនៃសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលរបស់អ្នកអាចនឹងមានលក្ខណៈខុសៗគ្នា សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលនេះ ផ្តល់នូវលំហាត់សម្រាប់មុខជំនាញទាំងអស់ដែលរៀបរាប់ខាងលើនោះ ។ អ្នកដែលមានជំនាញផ្នែកអាន សរសេរ និងលេខនព្វន្តកម្រិតខ្ពស់ មិនចាំបាច់បញ្ចប់គ្រប់មេរៀនទាំងអស់នោះឡើយ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គ្រប់មេរៀនទាំងអស់ត្រូវបានបង្ហាញ ។

## មេរៀនទី១ ៖ ហេតុអ្វីត្រូវធ្វើការកត់ត្រាបញ្ជី ?

### *ការពិភាក្សានៅពេលចាប់ផ្តើម*

**អ្នកសម្របសម្រួលគួរសួរសំណួរដូចខាងក្រោម ៖**

**តើអ្នកគិតថា អាជីវកម្មជាអ្វី ?**

- ចូរទុកអោយសិក្ខាកាមធ្វើការពិភាក្សាអំពីចម្លើយជាមុនសិន មុនពេលផ្តល់ជាយោបល់ផ្សេងៗ ។ ចម្លើយមួយចំនួនដូចខាងក្រោមនេះ គឺជាចម្លើយដែលល្អ ។

*(ចម្លើយ) សកម្មភាពទាំងអស់ដែលអ្នកធ្វើដើម្បីព្យាយាមរកប្រាក់ចំណូលជាប្រចាំ ត្រូវបានគេហៅថា អាជីវកម្ម ។ អាជីវកម្ម អាចជាការផលិតនិងលក់ទំនិញ ការទិញនិងការលក់ទំនិញ ឬការផ្តល់សេវាដល់ប្រជាជនទាំងឡាយ ។ ឧទាហរណ៍ រួមមាន ការឆ្អើរត្រីលក់ ការលក់ផលពីកសិដ្ឋាន ការលក់អង្ករនិងស្ករនៅផ្សារ ការសាងសង់ផ្ទះ ការកាត់ដេរសម្លៀកបំពាក់សម្រាប់អ្នកផ្សេង ឬការរត់ម៉ូតូឌុប ។*

**តើអ្នកធ្វើអាជីវកម្មប្រភេទអ្វី ?**

- ប្រសិនបើសិក្ខាកាមធ្វើការងារផ្នែកចិញ្ចឹមជ្រូក ចូរសួរសិក្ខាកាមម្នាក់ៗអំពីសកម្មភាពបង្កើតប្រាក់ចំណូលបន្ថែមទៀតដែលពួកគេធ្វើនៅផ្ទះ ។

**តើអ្នកជួបប្រទះបញ្ហាអ្វីខ្លះនៅក្នុងអាជីវកម្មផ្ទាល់ខ្លួនរបស់អ្នក ?**

- ចម្លើយទាំងអស់ គឺជាចម្លើយល្អ ។ ចូររកមើល និងរំឭកសិក្ខាកាមអំពីចំណុចដូចខាងក្រោម ៖

\+ *កង្វះដើមទុនដើម្បីទិញសត្វយកមកចិញ្ចឹម*

\+ *មានបញ្ហាក្នុងការលក់*

\+ *ត្រូវការលុយកាក់សម្រាប់ករណីបន្ទាន់*

\+ *គេអត់សងប្រាក់*

\+ *ត្រូវការលុយសម្រាប់ការរៀបចំពិធីផ្សេងៗ ។*

**តើអ្នកចាំទេថាតើលុយចំនួនប៉ុន្មានដែលចូល ហើយលុយចំនួនប៉ុន្មានដែលចេញ ?**

- ចម្លើយទាំងអស់ គឺជាចម្លើយល្អ ។ ប្រសិនបើអ្នកណាម្នាក់មានវិធីដើម្បីចងចាំចំនួនលុយចូល និងលុយចេញ ចូរអោយអ្នកនោះពន្យល់អំពីវិធីដែលគេធ្វើ ។

ចូរបន្តការពិភាក្សាស្រដៀងគ្នានេះ ដោយសួរសំណួរដូចខាងក្រោម :

- "តើអ្នកចងចាំថាអ្នកណាម្នាក់ជំពាក់ប្រាក់អ្នក ឬថាអ្នកជំពាក់ប្រាក់គេចំនួនប៉ុន្មាន ដោយរបៀបយ៉ាងដូចម្តេច ?"
- "តើអ្នកចងចាំនូវចំនួនម៉ោង ឬប្រាក់ដែលអ្នកបានចំណាយទៅលើពលកម្ម ចំនួនប្រាក់ដែលអ្នកជំពាក់មនុស្សដែលធ្វើការអោយអ្នក និងពេលដែលអ្នកត្រូវបើកប្រាក់ឈ្នួលអោយពួកគេ ដោយរបៀបណា ?"
- "តើអ្នកដឹងថាតើនៅពេលណាដែលអ្នកគួរទិញសម្ភារៈបន្ថែមសម្រាប់ដំណើរការផលិតកម្មរបស់អ្នក ឬផលិតផលដែលត្រូវលក់ និងថាតើត្រូវទិញចំនួនប៉ុន្មាននោះ យ៉ាងដូចម្តេច ?"

**តើនឹងមានរឿងអ្វីកើតឡើង ប្រសិនបើអ្នកភ្លេចអ្វីមួយនោះ ?**

**តើអ្នកគិតថា ការកត់ត្រាបញ្ជីមានអត្ថន័យយ៉ាងដូចម្តេច ?**

*- (ចម្លើយ) ការកត់ត្រាបញ្ជីមានន័យថា ការកត់ត្រានូវចំនួនប្រាក់ទាំងអស់ដែលចូល និងចេញនៅក្នុងកិច្ចប្រតិបត្តិការអាជីវកម្មរបស់អ្នក ការកត់ត្រាទុកនូវរបស់របរដែលអ្នកប្រើប្រាស់នៅក្នុងអាជីវកម្មរបស់អ្នក ការកត់ត្រាទុកនូវចំនួនប្រាក់ទាំងអស់ដែលអតិថិជនត្រូវសងអ្នកវិញ និងប្រាក់ទាំងអស់ដែលអ្នកត្រូវសងទៅអ្នកដទៃ ការកត់ត្រាទុកអំពីអ្នកណាខ្លះដែលបានធ្វើការអោយអ្នក តើពួកគេធ្វើការងារបានប៉ុន្មាន (ចំនួនម៉ោង ថ្ងៃ ឬបរិមាណការងារ) តើពួកគេត្រូវទទួលបានប្រាក់ឈ្នួលប៉ុន្មាន ហើយតើពេលណាដែលត្រូវបើកប្រាក់ឈ្នួលនោះអោយពួកគេ ។*

**តើអ្នកគិតថា ការកត់ត្រាបញ្ជីអាចជួយដល់អាជីវកម្មរបស់អ្នកយ៉ាងដូចម្តេចខ្លះ ?**

*- (ចម្លើយ) វានឹងជួយដល់អ្នកក្នុងការធ្វើសេចក្តីសម្រេចចិត្តកាន់តែប្រសើរឡើងអំពីអាជីវកម្មរបស់អ្នក ដើម្បីអ្នកអាចរកបានប្រាក់ចំណូលកាន់តែច្រើនថែមទៀត ។*

**<u>ចំណុចសំខាន់ៗដែលត្រូវរៀន</u>**

កំណត់សម្គាល់ : សំណួរខាងលើនេះនឹងបង្កើតបាននូវគំនិតជាច្រើន ប៉ុន្តែអ្នកសម្របសម្រួលគួរតែបិទកិច្ចពិភាក្សាដោយគូសបញ្ជាក់ឡើងវិញនូវចំណុចដូចខាងក្រោម :

**សារៈសំខាន់នៃការកត់ត្រាបញ្ជី**

ការកត់ត្រាបញ្ជីមានសារៈសំខាន់ ពីព្រោះអ្នកមិនអាចចងចាំនូវអ្វីៗគ្រប់រឿងបានទេ ។ ការចងចាំគឺមិនល្អគ្រប់គ្រាន់សម្រាប់ការវិភាគ និងការធ្វើផែនការបានត្រឹមត្រូវឡើយ ។ អត្ថប្រយោជន៍នៃការកត់ត្រាបញ្ជីជាទៀងទាត់ គឺ :

- អ្នកនឹងដឹងអំពីចំនួនប្រាក់ដែលអ្នកបានទទួល ចំនួនប្រាក់ដែលអ្នកបានចំណាយ និងរបៀបដែលអ្នកបានចំណាយប្រាក់ ។
- អ្នកអាចគណនាដឹងថាតើអ្នកកំពុងចំណេញ ឬក៏ខាត ។
- អ្នកនឹងអាចធ្វើសេចក្តីសម្រេចចិត្តបានកាន់តែល្អប្រសើរអំពីពេលវេលា និងអ្វីដែលត្រូវទិញ និងលក់ ។
- អ្នកអាចរក្សាទុកនូវកំណត់ត្រាអំពីចំនួនលុយចូលនិងចេញនៅក្នុងគម្រោងជាក្រុម ដូច្នេះអ្នកអាចទប់ស្កាត់ការប្រើប្រាស់លុយកាក់មិនត្រឹមត្រូវ និងជៀសវាងនូវការមិនទុកចិត្តគ្នាក្នុងចំណោមសមាជិកក្រុម ។
- ដោយធ្វើការប្រៀបធៀបបញ្ជីជាក់ស្តែងរបស់អ្នកជាមួយនឹងថវិកាដែលបានគ្រោងទុករបស់អ្នក អ្នកអាចកំណត់ថាតើអ្នកកំពុងធ្វើដំណើរលើមាគ៌ាត្រឹមត្រូវ ឬអត់ នៅក្នុងកិច្ចប្រតិបត្តិការអាជីវកម្មរបស់អ្នក ។

**ផលវិបាកនៃការកត់ត្រាបញ្ជីមិនបានល្អ**

- អ្នកនឹងមិនដឹងអំពីចំនួនប្រាក់ដែលអ្នកកំពុងរកបាន និងមិនដឹងថាតើអ្នកកំពុងចំណេញ ឬក៏ខាតប្រាក់ឡើយ ។
- អ្នកនឹងមិនដឹងអំពីមូលហេតុដែលអ្នកចំណេញ ឬខាតប្រាក់ឡើយ ។
- អ្នកនឹងមិនអាចធ្វើសេចក្តីសម្រេចចិត្តបានល្អ ដែលនឹងអាចអោយអ្នករកបានប្រាក់ចំណេញច្រើន និងទប់ស្កាត់អាជីវកម្មរបស់អ្នកពីការខាតបង់ប្រាក់បានឡើយ ។
- ក្នុងករណីដែលក្រុមមនុស្សជាច្រើនធ្វើការរួមគ្នា ការខ្វះប្រព័ន្ធកត់ត្រាបញ្ជីត្រឹមត្រូវ ជាញឹកញយតែងបណ្តាលទៅជាការមិនទុកចិត្តគ្នា និងការចោទគ្នាទៅវិញទៅមករវាងសមាជិកក្រុម ។

## មេរៀនទី២ ៖ លំហាត់_កិច្ចពិភាក្សាអំពីការកត់ត្រាបញ្ជី

**ឧទាហរណ៍ – ការសម្ដែងតួ**

អ្នកសម្របសម្រួលប្រាប់ទៅសិក្ខាកាមថា  អ្នកចង់អោយពួកគេពិភាក្សាអំពីស្ថានភាពមួយចំនួន  ពីព្រោះវានឹងជួយដល់សិក្ខាកាមអោយបានយល់កាន់តែច្បាស់អំពីសារសំខាន់នៃការកត់ត្រាបញ្ជី  ។  ចូរចែកសិក្ខាកាមជា ៣ក្រុម  ។ ចូរអានប្រធានបទនៃកិច្ចពិភាក្សាអោយក្រុមនីមួយៗស្ដាប់  ។

**ប្រធានបទសម្រាប់ក្រុមទី ១ ៖**

ស្ដ្រីម្នាក់មានមុខរបរលក់បន្លែនៅឯផ្សារ  ។ គាត់មិនកត់ត្រាអំពីចំនួនប្រាក់ចំណូល ឬចំណាយឡើយ  ។ ថ្ងៃមួយ  កូនប្រុសរបស់គាត់ត្រឡប់មកពីសាលារៀនវិញជាមួយនឹងលិខិតមួយច្បាប់ពីនាយកសាលា  ។ សាលាបានដំឡើងថ្លៃបង់សាលា  ហើយថ្លៃសាលានេះត្រូវតែបង់ជាបន្ទាន់  ។ ស្ដ្រីរូបនោះមានការព្រួយបារម្ភយ៉ាងខ្លាំង  ។ គាត់ដឹងថា  គាត់គ្មានប្រាក់ទេ  ។ គាត់ព្យាយាមរកនឹកទាំងអស់សង្ឃឹមថាតើគាត់រកបានប្រាក់ចំនួនប៉ុន្មាននៅក្នុងសប្ដាហ៍កន្លងទៅ និងថាតើគាត់បានចាយវាយទៅលើអ្វីខ្លះ  ។

**ប្រធានបទសម្រាប់ក្រុមទី ២ ៖**

ជាងឈើម្នាក់បានលក់ទូដាក់ចានមួយតម្លៃ ៧៥០.០០០រៀល  អោយទៅអតិថិជនមួយរូប  ។ នៅពេលដែលអតិថិជនរូបនោះមកយកទូ  គាត់បានប្រាប់ជាងឈើថា  គាត់ពុំមានប្រាក់អោយក្នុងពេលភ្លាមៗនេះទេ ប៉ុន្ដែគាត់បានសន្យាថានឹងសងនៅពេលដាច់ខែ  ។ នៅពេលដាច់ខែ  ជាងឈើព្យាយាមទៅយកប្រាក់របស់គាត់ដែលគេជំពាក់  ។ អតិថិជនរូបនោះប្រាប់ជាងឈើថា  គាត់ជំពាក់ជាងឈើតែ ៦៥០.០០០ រៀលប៉ុណ្ណោះ  ហើយថា  គាត់នឹងមិនសងប្រាក់លើសពីចំនួននេះឡើយ ! នៅពេលនោះ  ការជជែកគ្នាពោរពេញដោយកំហឹងក៏កើតមានឡើងរវាងអ្នកទាំងពីរ  ។ ប៉ុន្ដែ  ជាងឈើមិនមានភស្ដុតាងដែលបញ្ជាក់ថា  គាត់បានលក់ទូដាក់ចានអោយអតិថិជនរូបនោះក្នុងតម្លៃជឿ ៧៥០.០០០រៀល  ហើយគាត់ត្រូវតែព្រមទទួលយកប្រាក់  ៦៥០.០០០រៀល  ។

**ប្រធានបទសម្រាប់ក្រុមទី ៣ ៖**

ស្ដ្រីមួយក្រុមនៅក្នុងភូមិរបស់អ្នកមានហាងនំមួយ  ។ ពួកគេបានបែងចែកកិច្ចការគ្នាធ្វើដូចខាងក្រោម ៖

- ម្នាក់ជាអ្នកទិញគ្រឿងផ្សំសម្រាប់ធ្វើនំប៉័ង និងអុសដុត
- ម្នាក់ទទួលខុសត្រូវក្នុងការលក់នំប៉័ង
- សមាជិកផ្សេងទៀតទាំងអស់នៃក្រុម ជួយក្នុងការលុញម្សៅ និងដុតនំប៉័ង
- អ្នកកាន់លុយរបស់ក្រុម គឺទទួលខុសត្រូវទុកដាក់លុយកាក់អោយមានសុវត្ថិភាព  ។

ស្ត្រីដែលជាអ្នកលក់មិនកត់ត្រាអំពីចំនួនប្រាក់ដែលលក់បានទេ ។ នៅពេលណាដែលមានសាច់ប្រាក់ គាត់ប្រគល់ទៅអោយអ្នកកាន់លុយ ដែលយកលុយនោះទៅទុកក្នុងហិប ។ អ្នកកាន់លុយអោយលុយបន្តទៅអ្នកដែលទិញគ្រឿងផ្សំ និងអុស ។ អ្នកកាន់លុយ គឺជាមនុស្សដែលគួរអោយទុកចិត្តខ្លាំងណាស់ ប៉ុន្តែគាត់មិនចេះអាននិងសរសេរអក្សរទេ ។

នៅចុងខែ ក្រុមទាំងមូលចង់ដឹងថាតើពួកគេទទួលបានប្រាក់ចំណូលប៉ុន្មានពីការលក់នំប៉ុង ។ នៅពេលដែលពួកគេបើកហិបប្រាក់ ពួកគេឃើញថា ប្រាក់ដែលមាននៅក្នុងហិបគឺតិចជាងអ្វីដែលពួកគេបានរំពឹងទុក ។ គ្មាននរណាម្នាក់ដឹងថា ប្រាក់បាត់ទៅណាទេ ។ ក្រោយពេលពិភាក្សាគ្នា ពួកគេនាំគ្នាចោទប្រកាន់ស្ត្រីដែលជាអ្នកលក់ថាជាអ្នកលួចលុយ ។

**ការបញ្ចប់កិច្ចពិភាក្សា**

នៅក្រោយកិច្ចពិភាក្សានីមួយៗ ចូរសួរសិក្ខាកាមនូវសំណួរដូចខាងក្រោម ៖

**ក្រុមទី១**

- **តើអ្វីជាបញ្ហារបស់ស្ត្រីលក់បន្លែ ? តើគាត់គួរតែបានធ្វើអ្វីដើម្បីជៀសវាងបញ្ហានេះ ?**

*-(ចម្លើយ) គាត់បានចាយវាយប្រាក់អស់ដោយមិនបានគិតអំពីថ្លៃសាលារបស់កូនដែលគាត់ត្រូវបង់ ។ គាត់មិនទាំងចងចាំថា គាត់បានចាយវាយប្រាក់ទាំងនោះទៅលើអ្វីផងទេ ។ គាត់គួរតែបានកត់ត្រាបញ្ជីចំណូលនិងចំណាយរបស់គាត់ ហើយលៃលកទុកប្រាក់សម្រាប់ការបង់ថ្លៃសាលា ។*

**ក្រុមទី២**

- **តើហេតុអ្វីបានជាងឈើត្រូវបានគេបន្លំ ?**

*-(ចម្លើយ) ពីព្រោះគាត់មិនមានភស្តុតាងជាលាយលក្ខណ៍អក្សរដែលបញ្ជាក់អំពីចំនួនប្រាក់ដែលអតិថិជនជំពាក់រូបគាត់ ។*

**ក្រុមទី៣**

- **តើហេតុអ្វីបានជាសមាជិកក្រុមមានការខឹងសម្បា ? តើពួកគេគួរតែបានធ្វើអ្វីដើម្បីជៀសវាងនូវបញ្ហានេះ ?**

*-(ចម្លើយ) សមាជិកក្រុមខឹងសម្បា ដោយសារតែគ្មាននរណាម្នាក់ដឹងអំពីថាតើប្រាក់ដែលបានមកពីការលក់នំប៉ុងបាត់ទៅណា ? ប្រសិនបើពួកគេបានកត់ត្រាបញ្ជីទុក ពួកគេនឹងបានដឹងអំពីចំនួនប្រាក់ចំណូល និងប្រាក់ចំណាយនៃអាជីវកម្មរបស់ពួកគេ ។ ការកត់ត្រាបញ្ជីនេះ ក៏នឹងអាចជួយអោយពួកគេដឹងថា ពួកគេបានចំណេញ ឬមិនចំណេញផងដែរ ។*

**ចំណុចសំខាន់ដែលត្រូវរៀន ៖**

អ្នកសម្របសម្រួលគួរតែបិទវគ្គបណ្តុះបណ្តាល ដោយគូសបញ្ជាក់ថា នៅក្នុងគ្រប់ករណីជាឧទាហរណ៍ ការកត់ត្រាបញ្ជីដែលមានប្រសិទ្ធភាពនឹងជួយបញ្ចៀសបញ្ហា ។

## មេរៀនទី៣ ៖ ប្រភេទផ្សេងៗនៃការចំណាយ

**អ្នកសម្របសម្រួលគួរសួរ ៖ "តើមូលហេតុអ្វីបានជាវាជាការសំខាន់ដែលត្រូវចាត់ប្រភេទនៃការចំណាយផ្សេងៗគ្នា ?"**

ចម្លើយទាំងអស់ គឺជាចម្លើយល្អ ។ ចូររកមើលនិងរំឭកពួកគេអំពីចំណុចដូចខាងក្រោម ៖

*ព័ត៌មានដែលចុះនៅក្នុងចំណាត់ប្រភេទខុស ធ្វើអោយវាពិបាកក្នុងការកំណត់រកបញ្ហាណាស់ ប្រសិនបើអាជីវកម្មរបស់អ្នកជួបប្រទះការខាតបង់ប្រាក់ ។*

*អ្នកត្រូវការព័ត៌មានលម្អិតអំពីអាជីវកម្មរបស់អ្នក ប្រសិនបើអ្នកចង់ខ្ចីប្រាក់ ។*

**តើការចំណាយមានប៉ុន្មានប្រភេទ ?**

សិក្ខាកាមនឹងផ្តល់ចម្លើយចម្រុះ ប៉ុន្តែដើម្បីធានាអោយកិច្ចពិភាក្សាទៅមុខដោយរលូន អ្នកសម្របសម្រួលធ្វើការណែនាំអោយស្គាល់នូវប្រភេទនៃការចំណាយ ដែលចេញពីលទ្ធផលនៃការស្រាវជ្រាវអំពីគម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា ។ អ្នកសម្របសម្រួលបិទរូបភាពចំនួន ១២ នៅលើក្តារខៀន ប៉ុន្តែទុកចន្លោះខ្លះដើម្បីគេអាចសរសេរព័ត៌មានបន្ថែមនៅខាងក្រោមរូបភាពនីមួយៗបាន ។

អ្នកសម្របសម្រួលសួរអោយសិក្ខាកាមឆ្លើយថាតើរូបភាពនីមួយៗតំណាងអោយអ្វី ។

| ការទិញសត្វ | ចំណី | ឱសថ និងវ៉ាក់សាំង | ឧបករណ៍ និងសម្ភារៈ | ពលកម្ម | អគារ និងការថែទាំ | ការលក់ |
|---|---|---|---|---|---|---|
|  |  |  |  |  |  |  |
| កូនជ្រូក | ចំណីសត្វផ្សំ | វ៉ាក់សាំង | ឧបករណ៍សម្រាប់ដាក់ទឹកអោយជ្រូកផឹក | ប្រាក់ដែលអ្នកបើកអោយអ្នកផ្សេង ដែលធ្វើការងារអោយអ្នក | ការសាងសង់ទ្រុងជ្រូក | ជ្រូកធំ |
| មេជ្រូក | កន្ទក់ | ថ្នាំទម្លាក់សត្វល្អិត | ឧបករណ៍សម្រាប់ដាក់ចំណីអោយជ្រូកស៊ី | | ជួសជុលទ្រុងជ្រូក | កូនជ្រូក |
| ជ្រូកបា | ចុងអង្ករ | ឱសថសម្រាប់ | ឧបករណ៍សម្រាប់ | | ថ្លៃចំណាយផ្សេងៗ | ជ្រូកមេ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | គ្រាប់ពោត<br>សណ្តែកសៀង<br>បាយស្រា<br>កាកសំណល់បាយ<br>វីតាមីន<br>អ្វីៗផ្សេងទៀត ដែលអ្នកដាក់ចូលក្នុងចំណី | | ព្យាបាលជ្រូកឈឺ<br>ថ្លៃពេទ្យសត្វ | | ជួសជុល<br>ធុង<br>ទុយោទឹកសម្រាប់លាងសម្អាត<br>ឧបករណ៍សម្រាប់ប្រើក្នុងការលាងសម្អាត | | | | | ជ្រូកបា |

**តើការចំណាយអ្វីខ្លះ ដែលអាចចុះនៅក្នុងចំណាត់ប្រភេទទាំងនេះ ?**

សិក្ខាកាមនឹងផ្តល់ចម្លើយជាច្រើន ។ វានឹងមានភាពខុសគ្នាខ្លះនៅក្នុងមតិយោបល់អំពីការចំណាយមួយចំនួន និងកូឡោនដែលវាស្ថិតនៅ ។ ឧទាហរណ៍ ញញួរអាចនឹងស្ថិតនៅក្រោមកូឡោនឧបករណ៍ និងសម្ភារៈ ឬកូឡោន អគារ និងការថែទាំ ។ អ្នកសម្របសម្រួលគួរប្រាប់អ្នកចូលរួមកុំអោយគិតពីរឿងលម្អិតខ្លាំងពេក ប៉ុន្តែផ្តោតសំខាន់ទៅលើការកត់ត្រាថ្លៃលក់ និងថ្លៃចំណាយផ្សេងៗអោយមានភាពស៊ីគ្នា និងត្រឹមត្រូវ ។

| ការចំណាយលើការបង្កាត់ពូជ | ដឹកជញ្ជូន ប្រេងឥន្ធនៈ និងទូរស័ព្ទ | ការជួលអគារ ឬតូប នៅផ្សារ | ថ្លៃកាប់ | ការចំណាយផ្លូវការ |
|---|---|---|---|---|
|  |  |  |  |  |
| ការជួលជ្រូកបា | ម៉ូតូ | ថ្លៃជួលតូបនៅផ្សារ | ថ្លៃបង់ទៅអោយទីសត្តឃាតដ្ឋាន | ថ្លៃបង់ទៅអោយមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ការបង្កាត់ពូជសិប្បនិម្មិត<br><br>ទឹកកាមជ្រូកបា | | វ៉ីម៉ាក<br><br>ការជួសជុល<br><br>សាំង<br>ថ្លៃទូរស័ព្ទ | | ថ្លៃជួលកន្លែងអាជីវកម្មនៅក្បែរទីសត្តឃាតដ្ឋាន<br><br>ថ្លៃជួលហាង ឬកន្លែងលក់ដូរផ្សេងទៀត | | | | លិខិតអនុញ្ញាតដឹកជញ្ជូន<br><br>ពន្ធអាករផ្សេងៗ |

**តើអាជីវកម្មជ្រូកប្រភេទណា ដែលបង់ថ្លៃចំណាយនីមួយៗក្នុងចំណោមចំណាយទាំងអស់នេះ ?**

សំណួរនេះនឹងបំផុសអោយមានកិច្ចពិភាក្សាទូលំទូលាយអំពីលក្ខណៈដែលផលិតករក្នុងអាជីវកម្មជ្រូកផ្សេងគ្នាមានការចំណាយខុសៗគ្នា ប៉ុន្តែអ្នកសម្របសម្រួលគួរតែបិទវគ្គដោយនិយាយថា :

*ប្រភេទ ១-៧ គឺសម្រាប់អ្នកចិញ្ចឹមជ្រូកបំប៉នយកសាច់*

*ប្រភេទ១-៨-១២ គឺសម្រាប់អ្នកបង្កាត់ពូជជ្រូកនិងអ្នកចិញ្ចឹមជ្រូកបំប៉នយកសាច់*

*ប្រភេទ ១-១២ គឺសម្រាប់អាជីវករទិញ-លក់ជ្រូក*

បន្ទាប់មកទៀត អ្នកសម្របសម្រួលនិយាយថា ផលិតករក្នុងអាជីវកម្មជ្រូកផ្សេងៗគ្នាគឺមានតម្រូវការខុសៗគ្នា ហើយនឹងត្រូវការទម្រង់បញ្ជីខុសៗគ្នា ផ្អែកទៅលើប្រភេទអាជីវកម្មដែលពួកគេមាន ។ ប៉ុន្តែសម្រាប់លំហាត់នេះ យើងនឹងប្រើប្រាស់ប្រភេទ ១-៧ ។ អ្នកសម្របសម្រួលបញ្ចប់ដោយនិយាយថា គោលការណ៍នៃការកត់ត្រាបញ្ជីដែលល្អ គឺដូចគ្នា ដោយមិនគិតអំពីចំនួនប្រភេទនៃចំណូលចំណាយ ដែលអ្នកមាន ឬអាជីវកម្មដែលអ្នកកំពុងធ្វើឡើយ ។

**<u>ចំណុចសំខាន់ដែលត្រូវរៀន</u>**

ចំណុចសំខាន់ៗដែលត្រូវរៀន គឺថា ការចាត់ប្រភេទនៃការចំណាយគឺសំខាន់សម្រាប់ការគ្រប់គ្រងអាជីវកម្មប្រកបដោយប្រសិទ្ធភាព និងថា អាជីវកម្មផ្សេងៗគ្នានឹងមានប្រព័ន្ធកត់ត្រាបញ្ជីខុសៗគ្នា ។

## មេរៀនទី៤ : លំហាត់អនុវត្តន៍ជ្រើសរើសប្រភេទនៃការចំណាយ

អ្នកសម្របសម្រួលណែនាំអំពីមេរៀននេះ ដោយធ្វើការកត់សម្គាល់ថា លំហាត់នេះគឺជាឱកាសសម្រាប់សិក្ខាកាមអនុវត្តនូវអ្វីដែលពួកគេទើបនឹងបានពិភាក្សារួចមក ។ អ្នកសម្របសម្រួលចែក**ឯកសារចែកចាយទី១** ដល់សិក្ខាកាម ។

អ្នកសម្របសម្រួលអានការចំណាយអោយសិក្ខាកាមស្តាប់ ឧទាហរណ៍ **ខ្ញុំបានទិញកូនជ្រូក ៥ ក្បាល ពីអ្នកចិញ្ចឹមជ្រូកឈ្មោះ សុខ តើការចំណាយនេះត្រូវចុះនៅក្រោមកូឡោននៃការចំណាយមួយណា ?** អ្នកសម្របសម្រួលរង់ចាំចម្លើយពីសិក្ខាកាម សួរបញ្ជាក់អំពីចម្លើយនោះ រួចហើយប្រាប់អោយសិក្ខាកាមគូសសញ្ញា X នៅក្នុងប្រអប់ដែលត្រឹមត្រូវ ។ បន្ទាប់មក អ្នកសម្របសម្រួលសួរសំណួរមួយទៀត **ខ្ញុំបានទិញចំណីសត្វម៉ាក Medivet ៦០ គីឡូក្រាមពីអ្នកលក់នៅក្នុងភូមិ តើត្រូវចុះការចំណាយនេះនៅក្រោមកូឡោនមួយណា ?** ដំណើរការនេះត្រូវធ្វើដដែលៗសម្រាប់គ្រប់មុខចំណាយទាំងអស់ដែលមានចុះនៅក្រោមកូឡោនបរិយាយ ។ កំណត់សម្គាល់ : អ្នកនឹងចាំបាច់ត្រូវអានយឺតៗ និងអានសាឡើងវិញប្រសិនបើចាំបាច់ ឬប្រសិនបើសិក្ខាកាមមានការភ័ន្តច្រឡំ ។

| **ចម្លើយគំរូ** | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
|---|---|---|---|---|---|---|---|
| | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| **បរិយាយ** |  |  |  |  |  |  |  |
| ទិញកូនជ្រូក ៥ក្បាលពីអ្នកបង្កាត់ជ្រូកនៅក្នុងឃុំ ឈ្មោះ សុខ | X | | | | | | |
| ទិញចំណីសត្វម៉ាក Medivet ៦០គីឡូពីអ្នកលក់ក្នុងភូមិ | | X | | | | | |
| ទិញវ៉ាក់សាំងសម្រាប់កូនជ្រូក ៥ក្បាលពីអ្នកលក់ក្នុងភូមិ | | | X | | | | |
| បើកលុយអោយជីដូនមួយ ឈ្មោះ សុផាត សម្រាប់ថ្ងៃសម្អាតទ្រុងជ្រូក | | | | | X | | |
| ទិញសម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូកពីហាងលក់គ្រឿងដែកនៅក្នុងភូមិ | | | | | | X | |
| ទិញឧបករណ៍ដាក់ទឹកអោយជ្រូកផឹកថ្មីចំនួន ៣ | | | | X | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ទិញឱសថដើម្បីព្យាបាលជ្រូកឈឺ | | | X | | | | |
| លក់ជ្រូក ៦ក្បាល ក្នុង១ក្បាល១ទម្ងន់ ៩០គីឡូ ទៅអោយអ្នកប្រមូលទិញឈ្មោះ តារា | | | | | | | X |

## ឯកសារចែកចាយទី ១ : លំហាត់អនុវត្តន៍ជ្រើសរើសប្រភេទនៃការចំណាយ

ចូរដាក់សញ្ញា X នៅក្នុងប្រអប់នៅក្រោមកូឡោនត្រឹមត្រូវសម្រាប់មុខចំណាយនីមួយៗ ។ មុខចំណាយទី១ ត្រូវបានធ្វើជាឧទាហរណ៍អោយអ្នករួចហើយ ។

| | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
|---|---|---|---|---|---|---|---|
| | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| **បរិយាយ** |  |  |  |  |  |  |  |
| ទិញកូនជ្រូក ៥ក្បាលពីអ្នកបង្កាត់ជ្រូកនៅក្នុងឃុំ ឈ្មោះ សុខ | X | | | | | | |
| ទិញចំណីសត្វម៉ាក Medivet ៦0គីឡូពីអ្នកលក់ក្នុងភូមិ | | | | | | | |
| ទិញវ៉ាក់សាំងសម្រាប់កូនជ្រូក ៥ក្បាលពីអ្នកលក់ក្នុងភូមិ | | | | | | | |
| បើកលុយអោយជីដូនមួយ ឈ្មោះ សុផាត សម្រាប់ថ្លៃសម្អាតទ្រុងជ្រូក | | | | | | | |
| ទិញសម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូកពីហាងលក់គ្រឿងដែកនៅក្នុងភូមិ | | | | | | | |
| ទិញឧបករណ៍ដាក់ទឹកអោយជ្រូកផឹកថ្មីចំនួន ៣ | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ទិញឱសថដើម្បីព្យាបាលជ្រូកឈឺ | | | | | | | |
| លក់ជ្រូក ៦ក្បាល ក្នុង១ក្បាល៧ទម្ងន់ ៩0គីឡូ ទៅ<br>អោយអ្នកប្រមូលទិញឈ្មោះ តារា | | | | | | | |

# មេរៀនទី៥ : ការចុះបញ្ជីថ្លៃចំណាយ និងតម្លៃ

អ្នកសម្របសម្រួលណែនាំអំពីមេរៀននេះ ដោយធ្វើការកត់សម្គាល់ថា លំហាត់នេះគឺជាឱកាសសម្រាប់សិក្ខាកាមអនុវត្តនូវអ្វីដែលពួកគេទើបនឹងបានពិភាក្សារួចមក ។ អ្នកសម្របសម្រួលចែក**ឯកសារចែកចាយទី២** ដល់សិក្ខាកាម ។ អ្នកសម្របសម្រួលអានការចំណាយអោយសិក្ខាកាមស្តាប់ ឧទាហរណ៍ **ខ្ញុំបានទិញកូនជ្រូក ៥ក្បាល ពីអ្នកចិញ្ចឹមជ្រូកឈ្មោះ សុខ តម្លៃ ៣០០ ដុល្លារ តើការចំណាយនេះត្រូវចុះនៅក្រោមកូឡោននៃការចំណាយមួយណា ?** អ្នកសម្របសម្រួលរង់ចាំចម្លើយពីសិក្ខាកាម សួរបញ្ជាក់អំពីចម្លើយនោះ រួចហើយប្រាប់អោយសិក្ខាកាមសរសេរតម្លៃ ៣០០ដុល្លារ នៅក្នុងប្រអប់ដែលត្រឹមត្រូវ ។ បន្ទាប់មក អ្នកសម្របសម្រួលសួរសំណួរមួយទៀត **ខ្ញុំបានទិញចំណីសត្វម៉ាក Medivet ៦០គីឡូក្រាមពីអ្នកលក់នៅក្នុងភូមិ តម្លៃ ៥០ដុល្លារ តើត្រូវចុះការចំណាយនេះនៅក្រោមកូឡោនមួយណា ?** ដំណើរការនេះត្រូវធ្វើដដែលៗសម្រាប់គ្រប់មុខចំណាយទាំងអស់ដែលមានចុះនៅក្រោមកូឡោនបរិយាយ ។ កំណត់សម្គាល់ : អ្នកនឹងចាំបាច់ត្រូវអានយឺតៗ និងអានសាឡើងវិញប្រសិនបើចាំបាច់ ឬប្រសិនបើសិក្ខាកាមមានការភ័ន្តច្រឡំ ។

ខែ .................... ឆ្នាំ ២០ ..............

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | **ចម្លើយគំរូ : មេរៀនទី៥** | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
| | | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| | **បរិយាយ** |  |  |  |  |  |  |  |
| | ទិញកូនជ្រូក ៥ក្បាលពីអ្នកបង្កាត់ជ្រូកនៅក្នុងឃុំ ឈ្មោះ សុខ | $300 | | | | | | |
| | ទិញចំណីសត្វម៉ាក Medivet ៦០គីឡូពីអ្នកលក់ក្នុងភូមិ | | $50 | | | | | |
| | ទិញវ៉ាក់សាំងសម្រាប់កូនជ្រូក ៥ក្បាលពីអ្នកលក់ក្នុងភូមិ | | | $20 | | | | |
| | បើកលុយអោយជីដូនមួយ ឈ្មោះ សុផាត សម្រាប់ថ្ងៃសម្អាតទ្រុងជ្រូក | | | | | $3 | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ទិញសម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូកពីហាងលក់គ្រឿងដែកនៅក្នុងភូមិ | | | | | | $8 | |
| | ទិញឧបករណ៍ដាក់ទឹកអោយជ្រូកផឹកថ្មីចំនួន ៣ | | | | $4 | | | |
| | ទិញឱសថដើម្បីព្យាបាលជ្រូកឈឺ | | | $5 | | | | |
| | លក់ជ្រូក ៦ក្បាល ក្នុង១ក្បាលៗទម្ងន់ ៩0គីឡូ ទៅអោយអ្នកប្រមូលទិញឈ្មោះ តារា | | | | | | | $1150 |
| | | | | | | | | |

## ឯកសារចែកចាយទី ២ ៖ អនុវត្តជ្រើសរើសប្រភេទនៃការចំណាយ (២) ៖ ការបញ្ចូលតួលេខ

ចូរដាក់ចំនួនទឹកប្រាក់ជាដុល្លារ (ឬប្រាក់រៀល) សម្រាប់មុខចំណាយ ឬការលក់នីមួយៗ នៅក្នុងប្រអប់ត្រឹមត្រូវ ។ តួលេខទីមួយត្រូវបានដាក់បញ្ចូលជាឧទាហរណ៍សម្រាប់អ្នករួចហើយ ។ ចូរកុំខ្វល់ខ្វាយនឹងប្រអប់ដែលនៅសល់ ។ យើងនឹងប្រើវានៅពេលក្រោយ ។

ខែ .................... ឆ្នាំ ២០ ..............

| | | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| | **បរិយាយ** |  |  |  |  |  |  |  |
| | ទិញកូនជ្រូក ៥ក្បាលពីអ្នកបង្កាត់ជ្រូកនៅក្នុងឃុំ ឈ្មោះ សុខ | $300 | | | | | | |
| | ទិញចំណីសត្វម៉ាក Medivet ៦០គីឡូពីអ្នកលក់ក្នុងភូមិ | | | | | | | |
| | ទិញវ៉ាក់សាំងសម្រាប់កូនជ្រូក ៥ក្បាលពីអ្នកលក់ក្នុងភូមិ | | | | | | | |
| | បើកលុយអោយជីដូនមួយ ឈ្មោះ សុផាត សម្រាប់ថ្លៃសម្អាតទ្រុងជ្រូក | | | | | | | |
| | ទិញសម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូកពីហាងលក់គ្រឿងដែកនៅក្នុងភូមិ | | | | | | | |
| | ទិញឧបករណ៍ដាក់ទឹកអោយជ្រូកផឹកថ្មីចំនួន ៣ | | | | | | | |
| | លក់ជ្រូក ៦ក្បាល ក្នុងមួយក្បាលទម្ងន់៩០គីឡូទៅអោយអ្នកប្រមូលទិញ ឈ្មោះ តារា | | | | | | | |
| | | | | | | | | |

## មេរៀនទី៦ ៖ ការបំពេញបញ្ជីចំណាយប្រចាំខែ

**អ្នកសម្របសម្រួលសួរ ៖**

**តើកិច្ចការពីរយ៉ាងដែលត្រូវការចាំបាច់ដើម្បីធ្វើអោយបញ្ជីចំណាយប្រចាំខែមានលក្ខណៈពេញលេញ មានអ្វីខ្លះ ?**

អ្នកចូលរួមនឹងផ្តល់ចម្លើយផ្សេងៗគ្នា ប៉ុន្តែអ្នកសម្របសម្រួលគួរតែផ្តល់ចម្លើយចុងក្រោយថា

*ចុះថ្ងៃខែសម្រាប់ចំណាយនិងចំណូលនីមួយៗ ។*

*បូកចំនួនសរុបសម្រាប់ កូឡោននីមួយៗដើម្បីបានជាចំនួនសរុបប្រចាំខែ ។*

**តើព័ត៌មានអ្វីដែលត្រូវសរសេរនៅក្នុងកូឡោន ខាងឆ្វេងបំផុតដើម្បីធ្វើអោយបញ្ជីនេះកាន់តែមានសារប្រយោជន៍ ?**

*(ចម្លើយ) "កាលបរិច្ឆេទ" ឬ "ពេលវេលាដែលការចំណាយ ឬការលក់កើតឡើង" ។*

បន្ទាប់ពីសំណួរនេះ ចូរប្រាប់អោយសិក្ខាកាមសរសេរពាក្យថា "កាលបរិច្ឆេទ" នៅផ្នែកខាងលើបំផុតនៃកូឡោនទី១ ។ នៅពេលដែលពួកគេបានធ្វើដូច្នេះរួចហើយ ចូរអានកាលបរិច្ឆេទខាងក្រោមនេះ ដើម្បីអោយពួកគេបំពេញសម្រាប់មុខចំណាយនីមួយៗ ។ ចូរពន្យល់ថា កាលបរិច្ឆេទ ជាធម្មតាត្រូវសរសេរដោយដាក់លេខរៀងនៃថ្ងៃនៅខាងមុខលេខរៀងនៃខែ ។ កំណត់សម្គាល់ ៖ ចូរអានព័ត៌មាននេះអោយ ញូៗ និងយឺតៗ ដើម្បីទុកឱកាសអោយសិក្ខាកាមទាំងអស់អាចសរសេរកាលបរិច្ឆេទទាំងនេះបានត្រឹមត្រូវ ។

| | |
|---|---|
| 1/9 | ថ្ងៃ ១ កញ្ញា |
| 10/9 | ថ្ងៃ ១០ កញ្ញា |
| 11/9 | ថ្ងៃ ១១ កញ្ញា |
| 18/9 | ថ្ងៃ ១៨ កញ្ញា |
| 20/9 | ថ្ងៃ ២០ កញ្ញា |
| 26/9 | ថ្ងៃ ២៦ កញ្ញា |
| 29/9 | ថ្ងៃ ២៩ កញ្ញា |
| 30/9 | ថ្ងៃ ៣០ កញ្ញា |

ចូរពិនិត្យអោយប្រាកដថា សិក្ខាកាមគ្រប់រូបបំពេញកាលបរិច្ឆេទបានត្រឹមត្រូវគ្រប់គ្នា ។

**អ្នកសម្របសម្រួលគួរសួរថា :**

**តើបញ្ជីចំណាយនេះសម្រាប់ខែណា ?**

*(ចម្លើយ) "ខែកញ្ញា"*

នៅក្រោយពេលសួរសំណួរនេះហើយ ចូរប្រាប់អោយសិក្ខាកាមសរសេរ "ខែកញ្ញា ឆ្នាំ២០០៨" នៅផ្នែកខាងលើនៃតារាងបញ្ជីលេខ២ ។

**អ្នកសម្របសម្រួលគួរសួរ :**

**តើអ្វីផ្សេងទៀតដែលខ្វះនៅលើបញ្ជីនេះ ដែលនឹងធ្វើអោយបញ្ជីរឹតតែមានសារប្រយោជន៍នៅដំណាច់ខែ ?**

ចូរទទួលយកចម្លើយ ហើយលើកទឹកចិត្តសិក្ខាកាមអោយបញ្ចេញជាគំនិតយោបល់ផ្សេងៗ ប៉ុន្តែប្រសិនបើពួកគេមានបញ្ហា ចូរប្រាប់អោយពួកគេមើលប្រអប់ទទេនៅផ្នែកខាងក្រោមបំផុតនៃទំព័រ ។ ប្រសិនបើចាំបាច់ ចូរសួរសិក្ខាកាមថាតើមូលហេតុអ្វីបានជាពួកគេគិតថាមានប្រអប់ទទេនៅផ្នែកខាងក្រោមបំផុតនៃទំព័រ ។

*(ចម្លើយ) ប្រអប់ទទេទាំងនេះគឺទុកសម្រាប់អ្នកធ្វើការគណនាចំនួនសរុបសម្រាប់ប្រភេទនីមួយៗនៃចំណាយនិងចំណូលដែលអ្នកបានទទួលនៅក្នុងមួយខែ ។*

ចូរផ្តល់យោបល់អោយពួកគេសរសេរពាក្យថា "សរុប" នៅក្នុងចន្លោះទទេនៅលើជួរផ្តេកក្រោមគេបង្អស់នៃតារាង ។ ចូរពិនិត្យអោយប្រាកដថា ពាក្យ "សរុប" ត្រូវបានសរសេរនៅក្នុងចន្លោះទទេនេះ ។ ខាងក្រោមនេះ គឺជាតារាងដែលបង្ហាញអំពីចំណុចសំខាន់ៗសម្រាប់សិក្ខាកាម ។ ចូរធ្វើយ៉ាងណាអោយប្រាកថា សិក្ខាកាមទាំងអស់យល់ច្បាស់អំពីចំណុចដែលបានបង្ហាញនេះ នៅមុនពេលបន្តលំហាត់ទៅមុខទៀត ។

# មេរៀនទី៦ (ត) គន្លឹះចម្លើយសម្រាប់អ្នកសម្របសម្រួល

ខែ កញ្ញា ឆ្នាំ២០០៨

| កាលបរិច្ឆេទ | បរិយាយ | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| **កាលបរិច្ឆេទ** | **បរិយាយ** |  |  |  |  |  |  |  |
| 1/9 | ទិញកូនជ្រូក ៥ក្បាលពីអ្នកបង្កាត់ជ្រូកនៅក្នុងឃុំ ឈ្មោះ សុខ | $300 | | | | | | |
| 10/9 | ទិញចំណីសត្វម៉ាក Medivet ៦០គីឡូពីអ្នកលក់ក្នុងភូមិ | | $50 | | | | | |
| 11/9 | ទិញវ៉ាក់សាំងសម្រាប់កូនជ្រូក ៥ក្បាលពីអ្នកលក់ក្នុងភូមិ | | | $20 | | | | |
| 18/9 | បើកលុយអោយជីដូនមួយ ឈ្មោះ សុផាត សម្រាប់ថ្ងៃសម្អាតទ្រុងជ្រូក | | | | | $3 | | |
| 20/9 | ទិញសម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូកពីហាងលក់គ្រឿងដែកនៅក្នុងភូមិ | | | | | | $8 | |
| 26/9 | ទិញឧបករណ៍ដាក់ទឹកអោយជ្រូកផឹកថ្មីចំនួន ៣ | | | | $4 | | | |
| 29/9 | ទិញឱសថដើម្បីព្យាបាលជ្រូកឈឺ | | | $5 | | | | |
| 30/9 | លក់ជ្រូក ៦ក្បាល ក្នុង១ក្បាល១ទម្ងន់ ៩០គីឡូ ទៅ | | | | | | | $1150 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | អោយអ្នកប្រមូលទិញឈ្មោះ តារា | | | | | | | |
| | **សរុប** | | | | | | | |

៣. សិក្ខាកាម គួរសរសេរពាក្យ
"**សរុប**" នៅត្រង់នេះ

## មេរៀនទី៧ ៖ ការបូកសរុបតួលេខតាមក្លោននីមួយៗ

អ្នកសម្របសម្រួលសួរ ៖

**"តើឥឡូវនេះ ត្រូវធ្វើអ្វីទៀតដើម្បីធ្វើអោយទម្រង់បញ្ជីមានលក្ខណៈពេញលេញ ?"**

*(ចម្លើយ) ជំហានចុងក្រោយសម្រាប់ទម្រង់បញ្ជីប្រចាំខែ គឺបូកសរុបការចំណាយនៅក្នុងក្លោននីមួយៗ*

ឧទាហរណ៍នេះមានលក្ខណៈសាមញ្ញជាពិសេស ពីព្រោះមានការតម្រូវអោយធ្វើលេខបូកតែមួយគត់ ។ សិក្ខាកាមត្រូវបូកថ្លៃចំណាយទៅលើឱសថ និងថ្លៃចំណាយទៅលើវ៉ាក់សាំងបញ្ចូលគ្នា ។ ក្លោនផ្សេងៗទៀតមានតួលេខតែមួយគត់ ។ អ្នកសម្របសម្រួលគួរតែកុំភ្លេចប្រាប់សិក្ខាកាមថា មានលេខតែមួយគត់ ដូច្នេះពួកគេមិនចាំបាច់ធ្វើការបូកលេខទេ ។ ប្រសិនបើមានលេខច្រើន ពួកគេអាចប្រើម៉ាស៊ីនគិតលេខ ឬម៉ាស៊ីនគិតលេខនៅក្នុងទូរស័ព្ទដៃរបស់ពួកគេ ដើម្បីធ្វើការបូកលេខ និងពិនិត្យផ្ទៀងផ្ទាត់កិច្ចការរបស់ពួកគេបាន ។

| ចម្លើយគំរូ : មេរៀនទី៥ | | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ចំណី | ឱសថ និងវ៉ាក់សាំង | ឧបករណ៍ និងសម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| កាលបរិច្ឆេទ | **បរិយាយ** |  |  |  |  |  |  |  |
| ១/៩ | ទិញកូនជ្រូក ៥ក្បាលពីអ្នកបង្កាត់ជ្រូកនៅក្នុងឃុំ ឈ្មោះ សុខ | ៣០០ ដុល្លារ | | | | | | |
| ១០/៩ | ទិញចំណីសត្វម៉ាក Medivet ៦០គីឡូពីអ្នកលក់ក្នុងភូមិ | | ៥០ ដុល្លារ | | | | | |
| ១១/៩ | ទិញវ៉ាក់សាំងសម្រាប់កូនជ្រូក ៥ក្បាលពីអ្នកលក់ក្នុងភូមិ | | | ២០ ដុល្លារ | | | | |
| ១៨/៩ | បើកលុយអោយជីដូនមួយ ឈ្មោះ សុផាត សម្រាប់ថ្លៃសម្អាតទ្រុងជ្រូក | | | | | ៣ ដុល្លារ | | |
| ២០/៩ | ទិញសម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូកពីហាងលក់គ្រឿងដែកនៅក្នុងភូមិ | | | | | | ៨ ដុល្លារ | |
| ២៦/៩ | ទិញឧបករណ៍ដាក់ទឹកអោយជ្រូកផឹកថ្មីចំនួន ៣ | | | | ៤ ដុល្លារ | | | |
| ២៩/៩ | ទិញឱសថដើម្បីព្យាបាលជ្រូកឈឺ | | | ៥ ដុល្លារ | | | | |
| ៣០/៩ | លក់ជ្រូក ៦ក្បាល ក្នុង១ក្បាល១ទម្ងន់ ៩០គីឡូ ទៅអោយអ្នកប្រមូលទិញឈ្មោះ តារា | | | | | | | ១.១៥០ ដុល្លារ |
| | **សរុបប្រចាំខែ** | ៣០០ ដុល្លារ | ៥០ ដុល្លារ | ២៥ ដុល្លារ | ៤ ដុល្លារ | ៣ ដុល្លារ | ៨ ដុល្លារ | ១.១៥០ ដុល្លារ |

**ចំណុចសំខាន់ដែលត្រូវរៀន**

ចំណុចសំខាន់ គឺការដាក់ព័ត៌មានដែលត្រូវតាមកូឡោនរបស់វា ចុះថ្ងៃខែ និងបូកលេខ ។

## មេរៀនទី៨ : ទំព័រសង្ខេបចំណូល និងចំណាយប្រចាំខែ

ទម្រង់លេខ ២ នេះ គឺជាការសង្ខេបចំណូល និងចំណាយប្រចាំខែ និងប្រចាំឆ្នាំ ជារបាយការណ៍លំហូរសាច់ប្រាក់ដ៏ងាយស្រួលយល់សម្រាប់អាជីវកម្មចិញ្ចឹមជ្រូក ឬអាជីវកម្មទិញ-លក់ជ្រូក ។ មកដល់ត្រឹមនេះ សិក្ខាកាមគួរតែមានជំនឿចិត្តគ្រប់គ្រាន់ជាមួយនឹងទម្រង់នៃតារាង ។ ការផ្ទេរព័ត៌មានពីទម្រង់មុន គឺមានភាពងាយស្រួលធម្មតាទេ ប៉ុន្តែតម្រូវអោយមានការគណនាមួយ ដោយបូកសរុបចូលគ្នានូវលេខទាំងអស់នៅលើជួរផ្តេកនៃតារាង ដូចបង្ហាញនៅខាងក្រោម ។

**ចែកឯកសារចែកចាយទី៣**

**អ្នកសម្របសម្រួលប្រាប់អោយសិក្ខាកាម :**

- រកមើលនៅលើជួរផ្តេកនៃតារាងដែលមានឈ្មោះខែដែលជិតដាច់ ( ទើបកន្លងផុត) ដោយនៅក្នុងឧទាហរណ៍នេះ គឺខែកញ្ញា ។
- នៅលើជួរផ្តេកនេះ សរសេរចំនួនសរុបសម្រាប់កូឡោននីមួយៗនៅក្នុងប្រអប់នៃកូឡោនដែលមានរូបនិងចំណងជើងដូចគ្នា ( ឧទាហរណ៍ ចំណី ពលកម្ម ។ល ។)
- ចុះចំនួនសរុបដែលបានមកពីកូឡោននីមួយៗនៅក្នុងប្រអប់ត្រឹមត្រូវ សម្រាប់ប្រភេទចំណាយខុសៗគ្នាទាំងអស់ និងសម្រាប់ការលក់ផងដែរ ។
- មានកូឡោនបន្ថែមមួយទៀត មានចំណងជើងថា "ចំណាយសរុប" ។ បូកលេខនៅក្នុងប្រអប់ចំណាយទាំងអស់ដែលស្ថិតនៅជួរផ្តេកដូចគ្នា ហើយសរសេរលទ្ធផលបូកសរុបនេះក្នុងកូឡោន "ចំណាយសរុប" ។
- ភាពខុសគ្នារវាង "ចំណាយសរុប" និង "ការលក់" សម្រាប់ខែនេះ បង្ហាញអោយឃើញថា អ្នកបានចំណេញ ឬក៏អត់ នៅក្នុងខែនេះ ។ <u>កំណត់សម្គាល់</u> : អ្នកចាំបាច់ត្រូវនិយាយយឺតៗ និងនិយាយសាឡើងវិញ ប្រសិនបើចាំបាច់ ឬប្រសិនបើសិក្ខាកាមមានការភ័ន្តច្រលំ ។

## នំព័រសង្ខេបចំណូល និងចំណាយប្រចាំខែ (ចម្លើយគំរូ)

| | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | | ថ្លៃលក់ |
|---|---|---|---|---|---|---|---|---|
| | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈផ្សេងៗ | ពលកម្ម | អគារ និង ការថែទាំ | ចំណាយសរុប | |
| **ខែ** |  |  |  |  |  |  | **ដុល្លារ/រៀល** |  |
| មិថុនា | | | | | | | | |
| កក្កដា | ចំណាយសម្រាប់ប្រភេទនីមួយៗត្រូវបានបូកបញ្ចូលគ្នា (សរុប) | | | | | | | |
| សីហា | → | | | | | | | |
| កញ្ញា | ៣០០ ដុល្លារ | ៥០ ដុល្លារ | ២០ ដុល្លារ | ៤ ដុល្លារ | ៣ ដុល្លារ | ៨ ដុល្លារ | ៣៨៥ ដុល្លារ | ១.១៥០ ដុល្លារ |
| តុលា | | | | | | | | |
| វិច្ឆិកា | | | | | | | | |
| ធ្នូ | | | | | | | | |
| សរុប | | | | | | | | |

## នំព័រសង្ខេបចំណូល និងចំណាយប្រចាំខែ (ត)

នៅពេលដែលចំនួនសរុបប្រចាំខែត្រូវបានផ្ទេរទៅទំព័រសង្ខេប ការចំណាយបូកសរុបបញ្ចូលគ្នាទៅស្មើនឹង ៣៨៥ដុល្លារ ។ ថ្លៃលក់ គឺ ១.១៥០ ដុល្លារ ។ អ្នកសម្របសម្រួលគួរគូសបញ្ជាក់ថា អ្នកចិញ្ចឹមជ្រូកជួនកាល ត្រូវរង់ចាំជាច្រើនខែទើបអាចលក់ជ្រូកចេញ ឬរកប្រាក់ចំណេញបាន និងថា ជ្រូកត្រូវចិញ្ចឹមជាច្រើនខែទើបធំធាត់សម្រាប់លក់ទៅអោយទីផ្សារបាន ។ នេះហើយជាមូលហេតុដែលគេត្រូវរក្សាទុក

បញ្ជីចំណាយ និងបញ្ជីលក់រៀងរាល់ខែ និងបំពេញទម្រង់បញ្ជីសង្ខេប ។ នៅចុងឆ្នាំ ឬនៅដំណាច់វដ្តនៃការចិញ្ចឹមជ្រូក អ្នកអាចមើលឃើញយ៉ាងច្បាស់នូវចំនួនប្រាក់ដែលអ្នករកបាន ប្រៀបធៀបជាមួយនឹងចំនួនប្រាក់ដែលអ្នកបានចំណាយ ។

## ឯកសារចែកចាយទី៣ ៖ សង្ខេបចំណាយប្រចាំឆ្នាំសម្រាប់អាជីវកម្មចិញ្ចឹមជ្រូក (ទម្រង់លេខ២)

| | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|
| | ការទិញសត្វ | ចំណី | ឱសថនិងវ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | ការចំណាយសរុប | |
| **ខែ** |  |  |  |  |  |  | $/RL |  |
| មករា | | | | | | | | |
| កុម្ភៈ | | | | | | | | |
| មីនា | | | | | | | | |
| មេសា | | | | | | | | |
| ឧសភា | | | | | | | | |
| មិថុនា | | | | | | | | |
| កក្កដា | | | | | | | | |
| សីហា | | | | | | | | |
| កញ្ញា | | | | | | | | |
| តុលា | | | | | | | | |
| វិច្ឆិកា | | | | | | | | |
| ធ្នូ | | | | | | | | |
| **សរុប** | | | | | | | | |

## មេរៀនទី៩ : លំហាត់អនុវត្តន៍ជាមួយនឹងការចំណាយនៃខែមួយទៀត

ដើម្បីពង្រឹងចំណុចសំខាន់ដែលត្រូវរៀន សិក្ខាកាមគួរត្រូវបានផ្តល់ឱកាសអោយធ្វើលំហាត់អនុវត្ត ។ នៅមុនពេលចាប់ផ្តើមធ្វើលំហាត់នេះ ចូរសួរសំណួរសិន ។

**អ្នកសម្របសម្រួលគួរចែកឯកសារចែកចាយទី ៤ ហើយសួរសំណួរខាងក្រោមនេះ :**

**"តើខ្ញុំគួរធ្វើយ៉ាងដូចម្តេចជាមួយនឹងទម្រង់នេះ ?"**

*(ចម្លើយ) មានជំហានចំនួន ៤ នៃការប្រើប្រាស់ទម្រង់នេះ គឺ :*

*ទីមួយ : បូកសរុបកូឡោនចំណាយ "ពីលើចុះក្រោម"*

*ទីពីរ : ផ្ទេរព័ត៌មានចូលទៅក្នុងឯកសារចែកចាយទី៣ : សង្ខេបចំណាយប្រចាំឆ្នាំសម្រាប់អាជីវកម្មចិញ្ចឹមជ្រូកបំប៉នយកសាច់ (ទម្រង់លេខ២)*

*ទីបី : គណនាថ្លៃចំណាយសរុបប្រចាំខែ ដោយបូកថ្លៃចំណាយនៅក្នុងកូឡោនចំណាយនីមួយៗបញ្ចូលគ្នា នៅលើឯកសារចែកចាយទី ៣*

*ទីបួន : គណនាថ្លៃចំណាយ និងថ្លៃលក់សរុបសម្រាប់រយៈពេល២ខែ ដោយបូកលេខក្នុងកូឡោននីមួយៗពីលើចុះក្រោម នៅលើឯកសារចែកចាយទី៣ ។*

អ្នកសម្របសម្រួលត្រូវពិនិត្យមើលលំហាត់អនុវត្តន៍បន្ថែមជាមួយនឹងប្រព័ន្ធកត់ត្រាបញ្ជីនេះ នៅមុនពេលបន្តទៅដល់ការសង្ខេបចុងក្រោយនូវចំណុចសំខាន់ៗដែលត្រូវរៀន ។

***កំណត់សម្គាល់សម្រាប់អ្នកពិនិត្យ : តើយើងត្រូវបង្ហាញទម្រង់ដែលបំពេញរួចសម្រាប់រយៈពេលពីរខែ នៅត្រង់នេះដែរឬទេ ?***

## ឯកសារចែកចាយទី៤ ៖ បញ្ជីថ្លៃចំណាយ និងថ្លៃលក់ប្រចាំខែ សម្រាប់អាជីវកម្មចិញ្ចឹមជ្រូកបំប៉នយកសាច់

**ខែតុលា ឆ្នាំ២០០៨**

| | | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| | **បរិយាយ** |  |  |  |  |  |  |  |
| 3/10 | ទិញចំណីសត្វម៉ាក Medivet ៥០ គ.ក. ពីអ្នកលក់នៅក្នុងភូមិ | | $44 | | | | | |
| 5/10 | ទិញសម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូកពីហាងលក់គ្រឿងដែក នៅក្នុងភូមិ | | | | | | $12 | |
| 10/10 | ទិញកូនជ្រូក ៨ក្បាលពីអ្នកបង្កាត់ពូជជ្រូកក្នុងភូមិឈ្មោះ វុទ្ធី | $450 | | | | | | |
| 14/10 | ទិញវ៉ាក់សាំងសម្រាប់កូនជ្រូក ៨ក្បាល ពីអ្នកលក់នៅក្នុងភូមិ | | | $20 | | | | |
| 15/10 | បើកប្រាក់អោយអ្នកជិតខាងឈ្មោះ ដារ៉ា សម្រាប់ការសម្អាត ទ្រុងជ្រូក | | | | | $4 | | |
| 15/10 | ទិញកូនសោរ (សម្រាប់មួលរឹត) ថ្មីចំនួន ៥ | | | | $4 | | | |
| 18/10 | ទិញឱសថដើម្បីព្យាបាលជ្រូកឈឺ | | | $8 | | | | |
| 29/10 | លក់ជ្រូក ៨ក្បាល ក្នុង១ក្បាល១ទម្ងន់ ៩០គ.ក. អោយទៅអ្នក ប្រមូលទិញ ឈ្មោះ សុភាព | | | | | | | $1220 |
| | | | | | | | | |

## មេរៀនទី១០ ៖ ការរំឭកឡើងវិញនូវចំណុចសំខាន់ៗ

**អ្នកសម្របសម្រួលគួរសួរ ៖**

**តើយើងបានរៀនអ្វីខ្លះនៅថ្ងៃនេះ ?**

សំណួរនេះនឹងទទួលបានចម្លើយជាច្រើន ប៉ុន្តែអ្នកសម្របសម្រួលគួរគូសបញ្ជាក់បន្ថែមនូវចំណុចដូចខាងក្រោម ៖

*ចាប់ផ្តើមធ្វើបញ្ជីចំណាយ និងការលក់សម្រាប់ខែនីមួយៗ ។*

*ចូរថតចម្លងទំព័រមិនទាន់បំពេញព័ត៌មាននៃទម្រង់លេខ ១ នៅមុនពេលចាប់ផ្តើម ដើម្បីមានទម្រង់ជាស្រេចសម្រាប់ខែថ្មីមួយទៀត ។*

*ចុះកាលបរិច្ឆេទ និងសរសេរបរិយាយសង្ខេបអំពីរៀងរាល់ថ្លៃចំណាយនិងមុខចំណាយនីមួយៗ និងចុះកាលបរិច្ឆេទ និងសរសេរបរិយាយសម្រាប់ការលក់នីមួយៗផងដែរ ។*

*បញ្ចូលចំនួននៃថ្លៃចំណាយទៅតាមជួរត្រឹមត្រូវនៅក្រោមរូបភាពដែលត្រូវនឹងកិច្ចការចំណាយរបស់អ្នក ( ដូចជា ការទិញសត្វ ចំណី ឱសថ ។ល ។) ។*

*បញ្ចូលចំនួនប្រាក់ដែលបានពី "ការលក់" នៅក្នុងកូឡោនដែលមានចំណងជើងថា "ការលក់" ។*

*នៅចុងខែ បូកលេខនៅក្នុង "កូឡោន" នីមួយៗបញ្ចូលគ្នាដើម្បីសរុបថ្លៃចំណាយសម្រាប់ប្រភេទនៃមុខចំណាយនីមួយៗ ។*

*កត់ត្រាចំនួនសរុបប្រចាំខែនៅក្នុងបញ្ជីសង្ខេបទៅតាមប្រអប់ត្រឹមត្រូវសម្រាប់ខែ ដើម្បីតាមដានថ្លៃលក់និងថ្លៃចំណាយសម្រាប់រយៈពេលពេញមួយឆ្នាំ ។*

**<u>ការបណ្តុះបណ្តាលឈានដល់ទីបញ្ចប់</u>**

## ឧបសម្ព័ន្ធ ១ : ការណែនាំសង្ខេបសម្រាប់អ្នកចិញ្ចឹមជ្រូក និងអាជីវករផ្សារលក់ជ្រូកដែលមានបទពិសោធន៍ក្នុងការកត់ត្រាបញ្ជី

**ការណែនាំសម្រាប់ការប្រើប្រាស់ទម្រង់លេខ ១ : បញ្ជីចំណូលនិងចំណាយប្រចាំខែ**

- ចាប់ផ្តើមធ្វើតារាងថ្មីនៅដើមខែនីមួយៗ ។

- កត់ត្រានូវរាល់ប្រតិបត្តិការដែលកើតឡើងនៅក្នុងខែ ទាំងថ្លៃផ្សេងៗ និងការចំណាយ ព្រមទាំងការលក់ ។

- ប្រសិនបើអស់ចន្លោះសម្រាប់កត់ត្រានៅលើទំព័រទីមួយក្នុងអំឡុងពេលនៃខែមួយ ចូរបន្តកត់ត្រាការចំណាយសម្រាប់ខែដដែលនៅលើទំព័រថ្មីមួយទៀត ។ បន្ទាប់មក ចាប់ផ្តើមខែថ្មី ជាមួយនឹងទំព័រថ្មីមួយទៀត ។

- នៅចុងខែ ចូរធ្វើការបូកសរុបលេខនៅក្នុងកូឡោននីមួយៗពីលើចុះក្រោម ។

- នៅផ្នែកខាងក្រោមបំផុតនៃកូឡោននីមួយៗ ចូរកត់ត្រាចូលនូវចំនួនសរុបសម្រាប់ប្រភេទនៃមុខចំណាយនីមួយៗនៅក្នុងប្រអប់នៅជួរផ្តេកក្រោមបង្អស់ ។ សម្រាប់ជាឧទាហរណ៍ដែលយើងបានឃើញនៅក្នុងទំព័រទីមួយ បញ្ជីចំណាយនឹងមានលក្ខណៈដូចរូបខាងក្រោមនេះ :

ខែ ....... ឆ្នាំ២០ ..........

| | | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| **កាលបរិច្ឆេទ** | **បរិយាយ** |  |  |  |  |  |  |  |
| ១/៩ | ទិញកូនជ្រូក ៥ក្បាលពីអ្នកបង្កាត់ជ្រូកនៅក្នុងឃុំ ឈ្មោះ សុខ | ៣០០ ដុល្លារ | | | | | | |
| ១០/៩ | ទិញចំណីសត្វម៉ាក Medivet ៦០គីឡូពីអ្នកលក់ក្នុងភូមិ | | ៥០ ដុល្លារ | | | | | |
| ១១/៩ | ទិញវ៉ាក់សាំងសម្រាប់កូនជ្រូក ៥ក្បាលពីអ្នកលក់ក្នុងភូមិ | | | ២០ ដុល្លារ | | | | |
| ១៨/៩ | បើកលុយអោយជីដូនមួយ ឈ្មោះ សុផាត សម្រាប់ថ្លៃសម្អាតទ្រុងជ្រូក | | | | | ៣ ដុល្លារ | | |
| ២០/៩ | ទិញសម្ភារៈដើម្បីជួសជុលដំបូលទ្រុងជ្រូកពីហាងលក់គ្រឿងដែកនៅក្នុងភូមិ | | | | | | ៨ ដុល្លារ | |
| ២៦/៩ | ទិញឧបករណ៍ដាក់ទឹកអោយជ្រូកផឹកថ្មីចំនួន ៣ | | | | ៤ ដុល្លារ | | | |
| ២៩/៩ | ទិញឱសថដើម្បីព្យាបាលជ្រូកឈឺ | | | ៥ ដុល្លារ | | | | |
| ៣០/៩ | លក់ជ្រូក ៦ក្បាល ក្នុង១ក្បាល១ទម្ងន់ ៩០គីឡូ ទៅអោយអ្នកប្រមូលទិញឈ្មោះ តារា | | | | | | | ១.១៥០ ដុល្លារ |
| | **សរុបប្រចាំខែ** | ៣០០ ដុល្លារ | ៥០ ដុល្លារ | ២៥ ដុល្លារ | ៤ ដុល្លារ | ៣ ដុល្លារ | ៨ ដុល្លារ | ១.១៥០ ដុល្លារ |

**ការណែនាំសម្រាប់ការប្រើប្រាស់ទម្រង់លេខ ២ : បញ្ជីសង្ខេបចំណូល និងចំណាយ**

- រកមើលជួរផ្តេកនៅលើទម្រង់ដែលមានឈ្មោះខែដែលកំពុងដាច់ ( ឈានដល់ទីបញ្ចប់) ឧទាហរណ៍ ខែកញ្ញា ។
- នៅលើជួរផ្តេកនេះ ចូរសរសេរចំនួនសរុបសម្រាប់ប្រភេទនៃការចំណាយនីមួយៗនៅក្នុងប្រអប់នៃកូឡោនដែលមានរូបភាព និងចំណងជើងដូចគ្នា ( ឧទាហរណ៍ ចំណី ពលកម្ម ។ល ។) ។
- កត់ត្រាចំនួនសរុបដែលបានមកពីកូឡោននីមួយៗ ចូលទៅក្នុងប្រអប់ដែលត្រឹមត្រូវ សម្រាប់គ្រប់ប្រភេទនៃការចំណាយខុសៗគ្នា និងសម្រាប់ការលក់ផងដែរ ។
- មានកូឡោនបន្ថែមមួយទៀត មានចំណងជើងថា "ចំណាយសរុប" ។ ចូរបូកលេខនៅក្នុងប្រអប់ចំណាយទាំងអស់ដែលនៅលើជួរផ្តេកជាមួយគ្នាចូលគ្នា រួចហើយកត់ត្រាលទ្ធផលលេខសរុបនៅក្នុងកូឡោន "ចំណាយសរុប" ។
- ភាពខុសគ្នារវាង "ចំណាយសរុប" និង "ថ្លៃលក់" សម្រាប់ខែ បង្ហាញអោយឃើញថា អ្នកបានចំណេញ ឬក៏អត់ នៅក្នុងខែនេះ ។

| MONTH | COSTS AND EXPENSES: Purchase of Animals | Feed | Medicine and Vaccine | Equipment or Tools | Labor | Buildings and Maintenance | TOTAL EXPENSES $/RL | SALES |
|---|---|---|---|---|---|---|---|---|
| JUNE | | | | | | | | |
| JULY | | | | | | | | |
| AUGUST | | | | | | | | |
| SEPTEMBER | $300 | $50 | $20 | $4 | $3 | $8 | $385 | $1150 |
| OCTOBER | | | | | | | | |
| NOVEMBER | | | | | | | | |
| DECEMBER | | | | | | | | |
| TOTAL | | | | | | | | |

ចំណាយសម្រាប់ប្រភេទនីមួយៗត្រូវបានបូកបញ្ចូលគ្នា (សរុប)

១. រៀងរាល់ខែ :
បូកឆ្លងខ្ទង់ចំណាយ

២. នៅចុងឆ្នាំ ឬចុងវដ្តនៃការចិញ្ចឹមជ្រូក បូកតាមខ្ទង់ពីលើចុះក្រោម ដើម្បីដឹងចំណាយសរុប និង ចំណេញ ឬខាតសម្រាប់រយៈពេលមួយ

នៅពេលដែលចំនួនសរុបប្រចាំខែត្រូវបានផ្ទេរទៅក្នុងបញ្ជីសង្ខេប ការចំណាយទាំងអស់សរុបទៅស្មើនឹង ៣៨៥ដុល្លារ ។ ថ្លៃលក់សរុបទៅបាន ១.១៥០ដុល្លារ ។ អ្នកចិញ្ចឹមជ្រូក ជួនកាល ត្រូវរង់ចាំជាច្រើនខែទើបអាចលក់ជ្រូកចេញ ឬរកប្រាក់ចំណេញបាន ។ ជ្រូកត្រូវចិញ្ចឹមជាច្រើនខែទើបធំធាត់សម្រាប់លក់ទៅអោយទីផ្សារបាន ។ នេះហើយជាមូលហេតុដែលគេត្រូវរក្សាទុក បញ្ជីចំណាយនិងបញ្ជីលក់រៀងរាល់ខែ និងបំពេញទម្រង់បញ្ជីសង្ខេប ។ នៅចុងឆ្នាំ ឬនៅដំណាច់វដ្តនៃការចិញ្ចឹមជ្រូក អ្នកអាចមើលឃើញយ៉ាងច្បាស់នូវចំនួនប្រាក់ដែលអ្នករកបាន ប្រៀបធៀបជាមួយនឹងចំនួនប្រាក់ដែលអ្នកបានចំណាយ ។

ទម្រង់លេខ ១ : បញ្ជីចំណូល និងចំណាយប្រចាំខែសម្រាប់ប្រតិបត្តិការចិញ្ចឹមជ្រូកបំប៉នយកសាច់ ខែ .................... ឆ្នាំ ២០ ................

| | | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ចំណី | ឱសថនិងវ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | |
| កាលបរិច្ឆេទ | បរិយាយ |  |  |  |  |  |  |  |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | សរុបប្រចាំខែ | | | | | | | |

ទម្រង់លេខ ១ : បញ្ជីចំណូលនិងចំណាយប្រចាំខែសម្រាប់ប្រតិបត្តិការបង្កាត់ពូជជ្រូកនិងចិញ្ចឹមជ្រូកបំប៉នយកសាច់ ខែ ..................... ឆ្នាំ ២០ .................

| | | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ថ្លៃបង្កាត់ពូជ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និង ការជួសជុល | |
| កាលបរិច្ឆេទ | បរិយាយ |  |  |  |  |  |  |  |  |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | សរុបប្រចាំខែ | | | | | | | | |

ទម្រង់លេខ ១ : បញ្ជីចំណូលនិងចំណាយប្រចាំខែសម្រាប់ប្រតិបត្តិការទិញ-លក់ជ្រូក ខែ .................... ឆ្នាំ ២០ ................

| | | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|---|
| | | ការទិញសត្វ | ចំណី | ការដឹកជញ្ជូន ប្រេងឥន្ធនៈ និង ទូរស័ព្ទ | ការជួលអគារ ឬទ្រុង | ការជួលពលកម្ម | ថ្លៃកាប់ | ថ្លៃបង់ពន្ធ ផ្សេងៗ | ថ្លៃលក់សត្វ ឬសាច់ |
| កាល-បរិច្ឆេទ | បរិយាយ |  |  |  |  |  |  |  |  |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | សរុបប្រចាំខែ | | | | | | | | |

ទម្រង់លេខ២ : បញ្ជីសង្ខេបចំណូលនិងចំណាយប្រចាំឆ្នាំសម្រាប់ប្រតិបត្តិការចិញ្ចឹមជ្រូកបំប៉នយកសាច់ ឆ្នាំ : ២០ .................

| | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | | ថ្លៃលក់ |
|---|---|---|---|---|---|---|---|---|
| | ការទិញសត្វ | ចំណី | ឱសថនិងវ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និងការថែទាំ | ការចំណាយសរុប | |
| **ខែ** |  |  |  |  |  |  | $/RL |  |
| មករា | | | | | | | | |
| កុម្ភៈ | | | | | | | | |
| មីនា | | | | | | | | |
| មេសា | | | | | | | | |
| ឧសភា | | | | | | | | |
| មិថុនា | | | | | | | | |
| កក្កដា | | | | | | | | |
| សីហា | | | | | | | | |
| កញ្ញា | | | | | | | | |
| តុលា | | | | | | | | |
| វិច្ឆិកា | | | | | | | | |
| ធ្នូ | | | | | | | | |
| **សរុប** | | | | | | | | |

ទម្រង់លេខ២ : បញ្ជីសង្ខេបចំណូលនិងចំណាយប្រចាំឆ្នាំសម្រាប់ប្រតិបត្តិការបង្កាត់ពូជជ្រូកនិងចិញ្ចឹមជ្រូកបំប៉នយកសាច់ ឆ្នាំ : ២០ .................

| | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | | | ថ្លៃលក់ |
|---|---|---|---|---|---|---|---|---|---|
| | ការទិញសត្វ | ថ្លៃបង្កាត់ពូជ | ចំណី | ឱសថ និង វ៉ាក់សាំង | ឧបករណ៍ និង សម្ភារៈប្រើប្រាស់ | ពលកម្ម | អគារ និង ការជួសជុល | ការចំណាយសរុប | |
| **ខែ** |  |  |  |  |  |  |  | $/RL |  |
| មករា | | | | | | | | | |
| កុម្ភៈ | | | | | | | | | |
| មីនា | | | | | | | | | |
| មេសា | | | | | | | | | |
| ឧសភា | | | | | | | | | |
| មិថុនា | | | | | | | | | |
| កក្កដា | | | | | | | | | |
| សីហា | | | | | | | | | |
| កញ្ញា | | | | | | | | | |
| តុលា | | | | | | | | | |
| វិច្ឆិកា | | | | | | | | | |
| ធ្នូ | | | | | | | | | |
| **សរុប** | | | | | | | | | |

| | ថ្លៃផ្សេងៗ និងការចំណាយ | | | | | | | ថ្លៃលក់ |
|---|---|---|---|---|---|---|---|---|
| | ថ្លៃទិញសត្វ | ចំណី | ការដឹកជញ្ជូន ប្រេងឥន្ទនៈ និងទូរស័ព្ទ | ថ្លៃជួល | ថ្លៃពលកម្ម | ថ្លៃកាប់ | ថ្លៃបង់ពន្ធផ្សេងៗ | ថ្លៃលក់សត្វ |
| **ខែ** |  |  |  |  |  |  |  |  |
| មករា | | | | | | | | |
| កុម្ភៈ | | | | | | | | |
| មីនា | | | | | | | | |
| មេសា | | | | | | | | |
| ឧសភា | | | | | | | | |
| មិថុនា | | | | | | | | |
| កក្កដា | | | | | | | | |
| សីហា | | | | | | | | |
| កញ្ញា | | | | | | | | |
| តុលា | | | | | | | | |
| វិច្ឆិកា | | | | | | | | |
| ធ្នូ | | | | | | | | |
| **សរុប** | | | | | | | | |